វិទ្យាស្ថានបណ្តុះបណ្តាល
និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

កម្មវិធីធនធានធម្មជាតិ និង បរិស្ថាន





របាយការណ៍ពិសេសលេខ ៥





ខែមករា ឆ្នាំ២០១២



# មាគ៌ាចីរភាពឆ្ពោះទៅរក ការសម្រេចគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍៖ ករណីសិក្សាប្រទេសកម្ពុជា

# មាគ៌ាចីរភាពឆ្ពោះទៅរកការសម្រេច គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ករណីសិក្សាប្រទេសកម្ពុជា

## របាយការណ៍ពិសេសលេខ ៥ ខ

ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន ជបសអ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ខែមករា ឆ្នាំ២០១២ ភ្នំពេញ កម្ពុជា

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

© **រក្សាសិទ្ធិឆ្នាំ២០១២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**)

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារនេះដែលអាចយកទៅចម្លងទុកឬផ្សព្វផ្សាយតាមទម្រង់និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វបសអ ។

ISBN-10: 99950–52–39-3

**មាគ៌ាចីរភាពឆ្ពោះទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស៖ ករណីសិក្សាប្រទេសកម្ពុជា**
**Sustainable Pathways for Attaining the Millennium Development Goals: Cambodia Case Study**

**របាយការណ៍ពិសេសលេខ ៥ ខ**

**ក្រុមស្រាវជ្រាវ៖**

**ណាំង តិរុណា យ៉េម ដារ៉ារដ្ឋ លន់ ពេជ្រតារា រស់ បានសុខ បណ្ឌិត កុយ រ៉ា**
**និង បណ្ឌិត** Rebecca Catalla

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ ទេ។*

**វិទ្យាស្ថាន** CDRI

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh    http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និងយូ សិទ្ធីរិទ្ធី
បកប្រែដោយ៖ ខេង សេង និង នន សុខចំរើន
បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ព T & S រាជធានីភ្នំពេញ

# មាតិកា


សេចក្តីថ្លែងអំណរគុណ....................................................................vii
បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ....................................................................viii
ខ្លឹមសារសង្ខេប....................................................................ix

I **សេចក្តីផ្តើម** .................................................................... 1
១.១ គោលបំណងនៃការសិក្សា ....................................................................2
១.២ សំណួរស្រាវជ្រាវ ....................................................................2

II **វិធីសាស្ត្រស្រាវជ្រាវ** ....................................................................3

២.១ ការជ្រើសរើសទីតាំង ....................................................................3
២.២ ក្រុមស្រាវជ្រាវ....................................................................4
*២.២.១ អ្នកចុះអង្កេត....................................................................4*
*២.២.២ គ្រួសារគំរូតាង....................................................................4*
*២.២.៣ ការរៀបចំ និងការបកប្រែបញ្ជីសំណួរ....................................................................4*
២.៣ ការងារចុះដល់កន្លែង ....................................................................4
*២.៣.១ ការពិភាក្សាក្រុមស្នូល....................................................................5*
*២.៣.២ ការធ្វើសម្ភាសន៍គ្រួសារ ....................................................................5*

III **លទ្ធផលស្រាវជ្រាវ** ....................................................................7

៣.១ ការពិពណ៌នាពីតំបន់សិក្សា....................................................................7
៣.២ ប្រភពចំណូល....................................................................8
៣.៣ ប្រភេទធនធាន ....................................................................9
៣.៤ សេវាកម្មផ្គត់ផ្គង់ ....................................................................10
*៣.៤.១ ដំណាំ ផ្លែឈើ និងបន្លែ ....................................................................10*
*៣.៤.២ សត្វចិញ្ចឹម និងបសុបក្សី .................................................................... 11*
*៣.៤.៣ ការនេសាទ ....................................................................12*
*៣.៤.៤ អាហារព្រៃ ....................................................................13*
*៣.៤.៥ ឈើព្រៃ និងផ្តៅ/វល្លិ៍....................................................................15*
*៣.៤.៦ ឱសថបុរាណធម្មជាតិ....................................................................16*
*៣.៤.៧ ឋាមពលជីវម៉ាស....................................................................17*
*៣.៤.៨ អាហារព្រៃផ្សេងទៀត.................................................................... 19*
*៣.៤.៩ ដីកសិកម្ម....................................................................20*
*៣.៤.១០ ទឹកសាប....................................................................20*

៣.៥ សេវាកម្មវប្បធម៌ ........ 21

*៣.៥.១ ទេសចរណ៍ ........ 21*

៣.៦ និន្នាការទូទៅ ........ 22

*៣.៦.១ សេវាកម្មអេកូឡូស៊ី ........ 22*

*៣.៦.២ សេវាកម្មប្រព័ន្ធអេកូឡូស៊ីជាធនធានដ៏សំខាន់ ........ 23*

*៣.៦.៣ កម្រិតភាពក្រីក្រ និង សេវាកម្មប្រព័ន្ធអេកូឡូស៊ី ........ 24*

IV **សេចក្តីសន្និដ្ឋាន** ........ 25

ឯកសារយោង ........ 27

ឧបសម្ព័ន្ធ ........ 28

បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ........ 46

## បញ្ជីរូបភាព


រូបភាព ១៖ ផែនទីបង្ហាញទីតាំងសិក្សា ........ 3
រូបភាព ២៖ ប្រភពចំណូលបឋមរបស់គ្រួសារ (ជាភាគរយ) ........ 9
រូបភាព ៣៖ ប្រភពចំណូលទី២ ក្នុងគ្រួសារ (ភាគរយ) ........ 9
រូបភាព ៤៖ របាយជាភាគរយនៃគ្រួសារសិក្សាគិតតាមការប្រមូល និងប្រើប្រាស់ធនធានផ្សេងៗ ........ 10
រូបភាព ៥៖ ប្រភេទដំណាំ ផ្លែឈើ និងបន្លែដាំដោយប្រជាជន (របាយជាភាគរយ) ........ 10
រូបភាព ៦៖ របាយជាភាគរយនៃគ្រួសារមានចិញ្ចឹមសត្វសម្រាប់លក់ និងបរិភោគ ........ 11
រូបភាព ៧៖ របាយជាភាគរយនៃគ្រួសារប្រមូលផលនេសាទ គិតតាមប្រភេទផលនេសាទ ........ 13
រូបភាព ៨៖ របាយជាភាគរយនៃគ្រួសារបេះប្រមូលអាហារព្រៃ បែងចែកតាមប្រភេទអាហារព្រៃ ........ 14
រូបភាព ៩៖ របាយជាភាគរយនៃគ្រួសារប្រមូលផលព្រៃឈើ និងផ្តៅ/វល្លិ៍ ........ 15
រូបភាព ១០៖ របាយជាភាគរយនៃគ្រួសារប្រមូលឱសថបុរាណធម្មជាតិ គិតតាមប្រភេទឱសថ ........ 17
រូបភាព ១១៖ របាយជាភាគរយនៃគ្រួសារប្រមូលឋាមពលជីវម៉ាសសម្រាប់លក់ និងប្រើប្រាស់ គិតតាមប្រភេទជីវម៉ាស ........ 18
រូបភាព ១២៖ របាយជាភាគរយនៃគ្រួសារប្រមូលអាហារព្រៃផ្សេងៗសម្រាប់ការប្រើប្រាស់ និងសម្រាប់លក់ បែងចែកតាមប្រភេទអាហារ ........ 20
រូបភាព ១៣៖ ការប្រើបាស្រ់ដីកសិកម្មតាមគ្រួសារ ........ 20
រូបភាព ១៤៖ ប្រភពទឹកប្រើប្រាស់ដោយគ្រួសារសិក្សាសម្រាប់គោលដៅផ្សេងៗ ........ 21
រូបភាព ១៥៖ និន្នាការរបស់គ្រួសារ ក្នុងការប្រមូលធនធានពីសេវាកម្មអេកូឡូស៊ីក្នុងតំបន់សិក្សា ........ 22
រូបភាព ១៦៖ តម្លៃសុទ្ធប្រចាំឆ្នាំជាមេធ្យាន របស់គ្រួសារសិក្សា បានមកពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី ........ 23


## បញ្ជីតារាង


តារាង ១៖ ក្របខ័ណ្ឌគំរូតាងសំរាប់ខេត្ត ភូមិ និងគ្រួសារត្រូវចុះសិក្សា ........ 4
តារាង ២៖ លក្ខណៈសំគាល់នៃភូមិចុះអង្កេត ........ 7
តារាង ៣៖ កម្រិតសារៈសំខាន់នៃ CPR/សេវាកម្មប្រព័ន្ធអេកូឡូស៊ីa/ កំណត់ដោយបណ្តាគ្រួសារបានសិក្សា ........ 8
តារាង ៤៖ ចំណូល (ជាដុល្លារ) របស់គ្រួសារសិក្សានៅភូមិកំពង់ត្នោត និងកញ្ជរ បានពីដំណាំ ផ្លែឈើ និងបន្លែ គិតតាមរដូវ ........ 11
តារាង ៥៖ ចំណូលតាមរដូវ (ជាដុល្លារ) របស់គ្រួសារសិក្សា បានពីសត្វចិញ្ចឹម និងបសុបក្សី នៅភូមិកំពង់ត្នោត និងកញ្ជរ ........ 12
តារាង ៦៖ ចំណូល (ដុល្លារ) បានពីការនេសាទរបស់គ្រួសារសិក្សានៅភូមិកំពង់ត្នោត និងកញ្ជរ គិតតាមរដូវ ........ 13
តារាង ៧៖ ចំណូលគ្រួសារសិក្សា (ដុល្លារ) បានពីការប្រមូលអាហារព្រៃ នៅភូមិកំពង់ត្នោត និងកញ្ជរ គិតតាមរដូវ ........ 14

តារាង ៨៖ ចំណូលរបស់គ្រួសារសិក្សា (ជាដុល្លារ) នៅភូមិកំពង់ត្នោត និងកញ្ជរ បានពីផលិតផលឈើ និងផ្តៅ/វល្លិ៍ គិតតាមរដូវ ... 16
តារាង ៩៖ ប្រាក់ចំណូល (ដុល្លារ) បានពីឱសថបុរាណធម្មជាតិរបស់គ្រួសារសិក្សា ក្នុងភូមិកំពង់ត្នោត និងកញ្ជរ គិតតាមរដូវ ... 17
តារាង ១០៖ ចំណូល (ដុល្លារ) បានពីការប្រមូលហាមពលជីវម៉ាស គិតតាមរដូវ... 18
តារាង ១១៖ ចំណូល(ជាដុល្លារ) របស់គ្រួសារសិក្សា បានពីការប្រមូលអាហារព្រៃផ្សេងៗ គិតតាមរដូវ... 19
តារាង ១២៖ ការបែងចែកគ្រួសារសិក្សាជាក្រុម តាមកម្រិតភាពក្រីក្រ និងការពឹងផ្អែកលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីចម្បង ៤ ... 24

# សេចក្ដីថ្លែងអំណរគុណ

ក្រុមស្រាវជ្រាវ[1]នៅ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវិទ្យាស្ថានបរិស្ថានទីក្រុងស្តុកខុម (SEI) ដែលបានផ្តល់មូលនិធិគាំទ្រដល់ការស្រាវជ្រាវនេះ។ យើងសូមថ្លែងអំណរគុណជាពិសេសចំពោះបណ្ឌិត Linn Persson ជាអ្នកស្រាវជ្រាវផ្នែកការអនុវត្តពិធីសារមុងរ៉េអាល់របស់ SEI ដែលបានផ្តល់អនុសាសន៍ស្ថាបនាដ៏មានប្រយោជន៍ សម្រាប់របាយការណ៍ព្រាងនៃគម្រោងនេះ។

សហសេវិកជាច្រើននៅ វបសអ សូមទទួលយកការអរគុណជាពិសេស សម្រាប់ការរួមចំណែកដ៏មានតម្លៃដល់ការសិក្សានេះ៖

លោក លន់ ពេជ្រតារា និង លោក រស់ បានសុខ បានជួយដល់ការវិភាគទិន្នន័យ និងផ្នែកបច្ចេកទេសបន្ថែម ដើម្បីបញ្ចប់របាយការណ៍នេះ ហើយបណ្ឌិត Rebecca Catalla ជាទីប្រឹក្សាផ្នែកស្រាវជ្រាវ បានជួយណែនាំក្រុមស្រាវជ្រាវបំពេញតាមការជួយមតិផ្សេងៗ និងកែលម្អរបាយការណ៍សម្រេច។

បុគ្គលិកផ្នែកធនធានធម្មជាតិ និងបរិស្ថានដទៃទៀត ដូចជា បណ្ឌិត កុយ រ៉ា លោក ចែម ផល្លា និងលោកស្រី សំ ស្រីមុំ បានជួយគាំទ្រយ៉ាងច្រើនក្នុងផ្នែកផ្សេងទៀតនៃគម្រោងនេះ។

លោក សូ សុវណ្ណារិទ្ធិ លោក ឈឹម ឈន់ និង បណ្ឌិត តុង គឹមស៊ុន ក៏បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសយ៉ាងសំខាន់ក្នុងអំឡុងពេលនៃការសិក្សា ជាពិសេសនៅពេលចាប់ផ្ដើម។

យើងខ្ញុំសូមអរគុណអ្នកគ្រប់គ្រងជាន់ខ្ពស់នៃ វបសអ គឺលោក Larry Strange ជានាយកប្រតិបត្តិ បណ្ឌិត Hossein Jalilian ជានាយកផ្នែកស្រាវជ្រាវ និងលោក អ៊ឹង ស៊ានលី ជានាយកផ្នែកប្រតិបត្តិការ ចំពោះការគ្រប់គ្រង និងផ្តល់មតិណែនាំដ៏មានតម្លៃ ដែលបានជំរុញ និងលើកទឹកចិត្តយើងខ្ញុំ ក្នុងការអភិវឌ្ឍរបាយការណ៍នេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមអរគុណដល់ការរួមចំណែក និងកិច្ចសហប្រតិបត្តិការដ៏សំខាន់របស់ក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាជននៅភូមិកំពង់ត្នោត ឃុំកូនសត្វ ខេត្តកំពត និងភូមិកញ្ជរ ឃុំកញ្ជរ ខេត្តក្រចេះ។ ប្រសិនបើមិនមានការចូលរួម និងផ្តល់ព័ត៌មានដ៏សម្បូរបែបពីអ្នកទាំងនោះទេ ការសិក្សានេះក៏មិនអាចសម្រេចទៅបានដែរ ។

ណាំង ភិរុណ
យ៉ែម ដារ៉ារដ្ឋ

1 ណាំង ភិរុណ, យ៉ែម ដារារដ្ឋ, លន់ ពេជ្រតារា, រស់ បានសុខ, បណ្ឌិត កុយ រ៉ា និង បណ្ឌិត Rebecca Catalla។

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| វបសអ | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា (Cambodia Millennium Development Goalds) |
| CPR | ធនធានទ្រព្យរួម (Common Property Resources) |
| FGD | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussion) |
| GMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សសាកលលោក (Global Millennium Development Goals) |
| MDGS | គោលដៅអភិវឌ្ឍន៍សហស្សវត្ស (Millennium Development Goals) |
| MOE | ក្រសួងបរិស្ថាន (Ministry of Environment) |
| MOP | ក្រសួងផែនការ (Ministry of Planning) |
| MOPS | ការសិក្សាពីការចាកផុតពីភាពក្រីក្រ (Moving Out of Poverty Study) |
| NAPA | កម្មវិធីសកម្មភាពជាតិដើម្បីបន្សុាំទៅនឹងការបម្រែបម្រួលអាកាសធាតុ (National Adaptation Programme of Action to Climate Change) |
| NBSAP | ផែនការសកម្មភាព និងយុទ្ធសាស្រ្តជាតិលើវិស័យជីវចម្រុះ (National Biodiversity Strategy and Action Plan) |
| NEAP | ផែនការសកម្មភាពជាតិលើវិស័យបរិស្ថាន (National Environmental Action Plan) |
| NTFP | អនុផលព្រៃឈើ (Non-Timber Forest Products) |
| PARD | កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទរបស់ វបសអ (Poverty, Agriculture and Rural Development Programme) |
| PPA | ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម (Participatory Poverty Assessment) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (Royal University of Phnom Penh) |
| SEI | វិទ្យាស្ថានបរិស្ថានទីក្រុងស្តុកខុម (Stockholm Environment Institute) |
| TWGFE | ក្រុមការងារបច្ចេកទេសផ្នែកព្រៃឈើ និងបរិស្ថាន (Technical Working Group on Forestry and Environment) |

# ខ្លឹមសារសង្ខេប

គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាឆ្នាំ២០០៣ (CMDG) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) រាជរដ្ឋាភិបាលកម្ពុជា បានកសាងឡើងដោយអនុឡោមតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សសាកលលោក (GMDG)។ ការកសាងផែនការទាំងនេះមានគោលដៅ ពង្រឹងកិច្ចការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ក្នុងបរិបទនៃការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីជាប្រយោជន៍ដល់ការវិវត្តខាងសេដ្ឋកិច្ច និងសង្គមកិច្ចនៃសហគមន៍។

រដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពយ៉ាងខ្ពស់លើការការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី ដើម្បីឈានទៅគួបបញ្ចូលគ្នានូវការអភិរក្សជីវចម្រុះនិងគោលគំនិតនៃការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាទូទៅ។ ក្នុងន័យនេះ រដ្ឋាភិបាលមានមូលដ្ឋានគាំទ្រអំពី រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) ផែនការសកម្មភាពជាតិលើវិស័យបរិស្ថាន (NEAP) ឆ្នាំ១៩៩៨-២០០២ អនុក្រឹត្យស្តីការគ្រប់គ្រងព្រៃសម្បទានឆ្នាំ២០០០ ច្បាប់ព្រៃឈើ (២០០២) អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច (២០០៥) និងកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ (NAPA) ឆ្នាំ២០០៦។

វិទ្យាស្ថានបរិស្ថានទីក្រុងស្តុកខុម (SEI) បានផ្តួចផ្តើមគំនិតចូលរួមចំណែកលើកកម្ពស់ការយល់ដឹងអំពីមាគ៌ាប្រកបដោយចីរភាព ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស (MDG) ដោយណែនាំឲ្យមានការគិតគូរពីប្រព័ន្ធអេកូឡូស៊ីក្នុងបរិបទធំទូលាយនៃការប្រែប្រួលអាកាសធាតុ និងធានានូវភាពធន់នៃអេកូឡូស៊ី និងសង្គម ក៏ដូចជាចីរភាពបរិស្ថានរយៈពេលវែង។ នៅកម្ពុជា គម្រោងនេះ បានអនុវត្តឡើងដោយមានកិច្ចសហការជាដៃគូជាមួយ វបសអ តាមរយៈករណីសិក្សាកម្រិតមូលដ្ឋាននានា ជាពិសេសនៅភូមិមួយក្នុងខេត្តក្រចេះ និងភូមិមួយទៀតក្នុងខេត្តកំពត ដែលសុទ្ធសឹងជាតំបន់ដែល វបសអ ធ្លាប់ចុះអង្កេតសម្រាប់ការសិក្សាពីការចាកផុតពីភាពក្រីក្រ (MOPS)។ ករណីសិក្សាទាំងនេះ មានបំណងបំពេញបន្ថែមដល់ការវិភាគថ្នាក់ជាតិ ដោយធ្វើការវិភាគថ្នាក់មូលដ្ឋានឲ្យបានច្រើនថែមទៀត អំពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី- ជីវភាពរស់នៅ/ទំនាក់ទំនងជាមួយការកាត់បន្ថយភាពក្រីក្រ ក្នុងតំបន់រងសម្ពាធធ្ងន់ធ្ងរខាងប្រព័ន្ធអេកូឡូស៊ី។ ការប្រមូលទិន្នន័យសម្រាប់ករណីសិក្សាទាំងនេះ បានផ្អែកលើការអង្កេតមួយដែលធ្វើឡើងលើ ៨០គ្រួសារ៖ ៤០គ្រួសារ ក្នុងភូមិកញ្ជរ នៅខេត្តក្រចេះ និង ៤០គ្រួសារទៀតក្នុងភូមិកំពង់ត្នោត ខេត្តកំពត។ អ្នកភូមិកញ្ជរភាគច្រើន ពឹងផ្អែកខ្លាំងលើផល និងអនុផលព្រៃឈើ រីឯអ្នកភូមិកំពង់ត្នោតភាគច្រើនពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីសមុទ្រ (ការនេសាទតាមតំបន់ឆ្នេរ និងស្រែអំបិល)។ ក្រៅពីអង្កេតគ្រួសារខាងលើ ក៏នៅមានការពិភាក្សាតាមក្រុមស្នូល (FGD) ចំនួន ៣ទៀត ជាមួយមេដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងតំណាងគ្រួសារនៃអ្នកភូមិមួយចំនួនខាងលើ។

លទ្ធផលបានបង្ហាញថា តម្លៃសុទ្ធមេដ្យានប្រចាំឆ្នាំនៃប្រាក់ចំណូលរបស់គ្រួសារ បានជាចម្បងពី ដំណាំ សត្វចិញ្ចឹម ឋាមពលជីវម៉ាស និងការនេសាទ បន្ទាប់មកទៀតមាន ឈើហ៊ុប និងផ្តៅ/វល្លិ៍ នៅខេត្តក្រចេះ និងអាហារបានពីព្រៃនៅខេត្តកំពត។ មានតែ ២-៣គ្រួសារប៉ុណ្ណោះ ដែលទទួលប្រាក់ចំណូលខ្ពស់ពីមុខជំនួញឈើហ៊ុប និងផ្តៅ/វល្លិ៍ ដែលមិនមែនជាប្រភពប្រាក់ចំណូលរយៈពេលវែងទេ ដោយសារក្រុមហ៊ុនសម្បទានរារាំងអ្នកភូមិមិនឲ្យចូលទៅរកធនធានទាំងនោះ។ គ្រួសារមានជីវភាពក្រីក្រ ទំនងជាពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីនេះខ្លាំងជាងគ្រួសារមធ្យម និងគ្រួសារធូរធារ។ ប៉ុន្តែលទ្ធភាពចូលទៅរកធនធានទាំងនោះ កំពុងថយចុះជាខ្លាំង។

សេវាកម្មបរិស្ថាន ដែលភាគច្រើនចូលរួមចំណែកក្នុងប្រាក់ចំណូលគ្រួសារនៅខេត្តសិក្សាទាំងពីរនេះ បានថយចុះជាបណ្តើរៗពីឆ្នាំ១៩៩៩ ដល់ ២០០៨។ និន្នាការធ្លាក់ចុះនេះ កើតឡើងដោយសារហេតុផលមួយចំនួន ដូចជា កំណើនប្រជាជននៅតំបន់មូលដ្ឋាន ការកាប់ព្រៃយកដីធ្វើចំការធំៗឬធ្វើកសិកម្ម ការហាមឃាត់ការចូលរកធនធានព្រៃឈើក្រោយពេលមានកិច្ចសន្យាព្រៃសម្បទាន កង្វះការតាមដាន និងវិធានការអនុវត្តច្បាប់នៅតែមានកម្រិត។ អ្នកភូមិបានប្រាប់ថា

ទន្លេកាន់តែរាក់ទៅៗ និងមានស្លែដុះកាន់តែច្រើនលើផ្ទៃទឹក ដោយសារសំណង់ទំនប់ទឹកនៅទន្លេមេគង្គប៉ែកខាងលើ ហើយរដូវប្រាំងមានរយៈពេលវែងជាងរដូវវស្សា រីឯអាកាសធាតុក៏កាន់តែក្តៅទៅៗ ហើយភ្លៀងធ្លាក់កាន់តែមិនទៀងទាត់។ សត្វល្អិតបំផ្លាញដំណាំក៏កើនឡើងដែរ ហើយអ្នកភូមិបានប្រើថ្នាំសម្លាប់សត្វល្អិតចង្រៃកាន់តែច្រើនឡើងដោយមិនបានគិតគូរត្រឹមត្រូវ។ និន្នាការថយចុះសេវាកម្មបរិស្ថាននេះ អាចកាត់បន្ថយអត្រាប្រាក់ចំណូលរបស់គ្រួសារ និងប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនមូលដ្ឋាន។ ដំណាលគ្នានេះដែរ បម្រែបម្រួលអាកាសធាតុអាចជះឥទ្ធិពលកាត់បន្ថយគុណភាពសេវាអេកូឡូស៊ី និងបង្កើនចំនួនជនក្រីក្រនៅជនបទ។

សកម្មភាពសមស្របមួយចំនួន គួរត្រូវអនុវត្តឡើង ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន គួរយកចិត្តទុកដាក់ខ្លាំងថែមទៀតដល់ការបង្ក្រាបសកម្មភាពខុសច្បាប់ ដែលអាចបង្កការរេចរិលធនធានធម្មជាតិ និងគួរធ្វើសកម្មភាពសមស្របជាប្រចាំមួយចំនួន ដើម្បីតាមដានការអនុវត្តកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងធានាថា ការអនុវត្តនោះ ស្របតាមបទបញ្ញត្តិព្រៃឈើរបស់កម្ពុជា (ឧទាហរណ៍ ច្បាប់ព្រៃឈើ គោលនយោបាយវិស័យព្រៃឈើជាតិ អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន និងអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច) ដែលសំដៅបង្កើតប្រាក់ចំណូលរដ្ឋ និងបង្កើនឱកាសការងារ ព្រមទាំងពង្រឹង និងធ្វើពិពិធកម្មជីវភាពរស់នៅក្នុងក្របខ័ណ្ឌការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើប្រព័ន្ធអេកូឡូស៊ី។ កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការបម្រែបម្រួលអាកាសធាតុ ដែលជាក្របខ័ណ្ឌមួយណែនាំអំពីការសម្របសម្រួល និងអនុវត្តគំនិតផ្តួចផ្តើមនៃការបន្សាំដោយប្រើវិធីសាស្ត្រមានការចូលរួម ក៏គួរអនុវត្តឲ្យបានល្អ ដើម្បីដោះស្រាយតម្រូវការបន្ទាន់ និងភ្លាមៗ របស់ប្រជាជននៅមូលដ្ឋាន ជួយឲ្យអ្នកភូមិអាចសម្របខ្លួនទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

# I
# សេចក្តីផ្តើម

ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហស្សវត្ស បានជំរុញយ៉ាងខ្លាំងឲ្យមានការជជែកវែកញែកជាអន្តរជាតិដ៏ទូលំទូលាយផ្នែកវិទ្យាសាស្ត្រនាបច្ចុប្បន្ន អំពីសារៈសំខាន់នៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីចំពោះមនុស្សជាតិ។ ការពង្រឹងការអភិរក្ស និងប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព ដើម្បីបង្កើនសុខុមាលភាពរបស់មនុស្សជាតិ ជាបញ្ហាដ៏សំខាន់។ រដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ការការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី ស្របតាមមាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា *"រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ និងធនធានជលផល"*។

ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) គឺជាក្របខ័ណ្ឌច្បាប់មូលដ្ឋាន សម្រាប់កិច្ចដំណើរការនៃក្រសួងបរិស្ថាន(MOE) ដោយបានកំណត់ពីការការពារ គ្រប់គ្រង និងពង្រឹងបរិស្ថាន ព្រមទាំងជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាព។ ផែនការសកម្មភាពជាតិលើវិស័យបរិស្ថានឆ្នាំ១៩៩៨-២០០២ (NEAP) មានគោលដៅបញ្ចូលបញ្ហាបរិស្ថាន ទៅក្នុងសកម្មភាពសេដ្ឋកិច្ច ដើម្បីធានានូវចីរភាពនៃសមត្ថភាពដំណើរការរបស់ប្រព័ន្ធអេកូឡូស៊ីកម្ពុជា។

ផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិលើវិស័យជីវចម្រុះឆ្នាំ២០០២ (NBSAP) បានកសាងឡើងដើម្បីបញ្ចូលការអភិរក្សជីវចម្រុះ និងគោលគំនិតនៃការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពទៅក្នុងយុទ្ធសាស្ត្ររួមដើម្បីកាត់បន្ថយភាពក្រីក្រ។NBSAPផ្តល់ជាក្របខ័ណ្ឌមួយសម្រាប់សកម្មភាពនៅគ្រប់កម្រិតដើម្បីបង្កើនផលិតភាពលក្ខណៈចម្រុះ និងភាពគង់វង្សនៃធនធានធម្មជាតិ។

ការធានាបានចីរភាពបរិស្ថាន ក៏មានបញ្ជាក់ផងដែរក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា (CMDG) ឆ្នាំ ២០០៣។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (២០០៦-២០១០) ចែងថា រដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ទៅលើបរិស្ថាន និងការអភិរក្ស ក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចនៅតាមសហគមន៍ជាប់ទាក់ទិន។

ការខិតខំប្រឹងប្រែងដោះស្រាយបញ្ហារេចរិលបរិស្ថាន ជាពិសេស ឱនភាពព្រៃឈើ និងធនធានទឹក នៅតែមិនទាន់ឆ្លើយតបបានទាំងស្រុងទៅនឹងគោលដៅ CMDG 2005 នោះទេ។ ធនធានធម្មជាតិរបស់កម្ពុជា កំពុងតែរងការខូចខាតគួរឲ្យកត់សម្គាល់។ គម្របព្រៃឈើកម្ពុជា មាន ៧៣% នៃផ្ទៃដីសរុបទូទាំងប្រទេសនៅឆ្នាំ១៩៦៥ តែបានធ្លាក់ចុះត្រឹម ៥៨,៧% នៅឆ្នាំ១៩៩៧ ទោះមានការដាំដើមឈើឡើងវិញបាន ១១.១២៥ហិកតាពីឆ្នាំ១៩៨៥ ដល់ ២០០២ ក្តី។ នៅឆ្នាំ២០០៧ ក្រុមការងារបច្ចេកទេសផ្នែកព្រៃឈើ និងបរិស្ថាន (TWGFE) បានរាយការណ៍ថា គម្របព្រៃឈើកម្ពុជាធ្លាក់ចុះពី ៦១% មកត្រឹម ៥៩% នៃផ្ទៃដីសរុបពីឆ្នាំ២០០២ ដល់ ២០០៦ គឺចុះទាបបន្តិចជាងគោលដៅ CMDG ដែលកំណត់ស្មើនឹង ៦០% (ពីឆ្នាំ២០០៥ ដល់ ២០១៥)។ ការធ្លាក់ចុះគម្របព្រៃ ២% ជាការបាត់ដីព្រៃឈើប្រមាណ ៣៧៣.៥១០ហិកតា(TWGFE 2007)។

## ១.១ គោលបំណងនៃការសិក្សា

នៅទូទាំងពិភពលោក កំពុងមានការពិភាក្សា និងពិគ្រោះយោបល់លើ វិធីសាស្ត្រមានប្រសិទ្ធភាពល្អជាងគេ សម្រាប់បង្កើតការយល់ដឹងកាន់តែប្រសើរអំពី មាគ៌ាប្រកបដោយចីរភាព ដើម្បីសម្រេចគោលដៅអភិវឌ្ឍសហស្សវត្ស (MDG) ដោយបានគិតគូរពីប្រព័ន្ធអេកូឡូស៊ី ក្នុងបរិបទធំទូលាយនៃការប្រែប្រួលអាកាសធាតុ។ គោលដៅនៃគំនិតផ្តួចផ្តើមរយៈពេល ២ឆ្នាំរបស់ SEI ស្តីពីមាគ៌ាប្រកបដោយចីរភាពដើម្បីសម្រេច MDG គឺមាន ១) បង្កើនចំណាប់អារម្មណ៍ ការយល់ដឹង និងចំណេះដឹងក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចចិត្ត ២) ផ្តល់ជាអនុសាសន៍ច្បាស់លាស់ផ្នែកគោលនយោបាយ និង ៣) ជួយជ្រោមជ្រែងដល់រដ្ឋាភិបាលស៊ុយអ៊ែត ពាក់ព័ន្ធនឹងសារៈសំខាន់នៃការបញ្ចូលបញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ទៅក្នុងយុទ្ធសាស្ត្រនានា ដើម្បីសម្រេច MDGs ឲ្យបាន និងធានានូវភាពធន់ខាងអេកូឡូស៊ី និងសង្គម ក៏ដូចជា ចីរភាពបរិស្ថានរយៈពេលវែង។

គំនិតផ្តួចផ្តើមនេះ តម្រូវឲ្យមានសកម្មភាព ៣សំខាន់ៗ ដើម្បីសម្រេចគោលដៅ៖

- ការពិនិត្យមើលគ្រប់ជ្រុងជ្រោយពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលចាំបាច់បំផុត ដើម្បីសម្រេច MDG ហើយនិងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើការផ្គត់ផ្គង់សេវាកម្មទាំងនេះ។
- ការពិគ្រោះយោបល់រវាងអ្នកពាក់ព័ន្ធអន្តរជាតិ លើជម្រើសគោលនយោបាយផ្សេងៗ និង
- ការចូលរួមក្នុងគោលនយោបាយថ្នាក់ជាតិ ដោយផ្អែកលើការវិភាគថ្នាក់មូលដ្ឋាន និងតំបន់ ដែលធ្វើឡើងនៅកម្ពុជា។

គម្រោងនេះមួយចំណែក អនុវត្តឡើងតាមរយៈករណីសិក្សាថ្នាក់មូលដ្ឋានចំនួន ៤កន្លែងក្នុងប្រទេសកម្ពុជា។ ករណីសិក្សានៅកម្ពុជា បានធ្វើឡើងនៅតាមភូមិក្នុងព្រៃតំបន់ខ្ពង់រាប តំបន់វាលទំនាប តំបន់នេសាទទឹកសាប និងតំបន់ឆ្នេរ។ វត្ថុបំណងនៃការសិក្សានេះ គឺបំពេញបន្ថែមការវិភាគថ្នាក់ជាតិ ដោយធ្វើការវិភាគកាន់តែច្រើនលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីថ្នាក់មូលដ្ឋាន ដែលមានដូចជា ការវិភាគពីទំនាក់ទំនងនៃការកាត់បន្ថយភាពក្រីក្រ/ការចិញ្ចឹមជីវិតជាដើម ក្នុងទីតាំងមួយចំនួនដែលតំណាងឲ្យតំបន់អាទិភាពក្នុងប្រព័ន្ធអេកូឡូស៊ី។ ដើម្បីធ្វើផែនការ និងអនុវត្តគំនិតផ្តួចផ្តើមនេះ SEI បានអញ្ជើញដៃគូថ្នាក់ជាតិ ឲ្យអនុវត្តករណីសិក្សាមួយចំនួន និងដើរតួនាទីសំខាន់ក្នុងការសន្ទនាថ្នាក់ជាតិ។

SEI និង វបសអ បានព្រមព្រៀងរួមដៃគ្នាចូលរួមក្នុងការងារពាក់ព័ន្ធគោលនយោបាយថ្នាក់ជាតិនៅកម្ពុជា ជាបឋមតាមរយៈ ការរៀបចំ និងសម្របសម្រួលកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ។ វបសអ បានទទួលគិតគូរ និងរៀបចំករណីសិក្សាចំនួនពីរ[2] គឺករណីមួយស្ថិតក្នុងភូមិមួយនៅខេត្តក្រចេះ និងមួយទៀតនៅក្នុងភូមិមួយនៅខេត្តកំពត។ ក្នុងការសិក្សាពីការចាកផុតពីភាពក្រីក្រ (MOPS) វបសអ ក៏ធ្លាប់បានចុះអង្កេតនៅភូមិទាំងពីរនេះដែរ។

## ១.២ សំណួរស្រាវជ្រាវ

ការសិក្សានេះ បានព្យាយាមឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

- តើសេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រភេទណា ដែលប្រជាជនមានលទ្ធភាពប្រើប្រាស់?
- តើការប្រែប្រួលអាកាសធាតុ ប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងជីវភាពប្រជាជនរបៀបណា ហើយតើប្រជាជនអាចទប់ទល់ ឬបន្សាំនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដោយរបៀបណា?
- តើជីវភាពប្រជាជនពឹងផ្អែកលើសេវាកម្មអេកូឡូស៊ីអ្វីខ្លះ?
- តើសេវាកម្មអេកូឡូស៊ីនីមួយៗ មានសារៈសំខាន់យ៉ាងណាចំពោះជីវភាពប្រជាជន?
- តើហានិយភ័យ និងភាពមិនប្រាកដប្រជាចំពោះប្រព័ន្ធអេកូឡូស៊ីអ្វីខ្លះ ដែលគេអាចកំណត់បាន?

---

2 សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ដែលជាដៃគូស្រាវជ្រាវទី២ របស់ SEI នៅកម្ពុជា បានអនុវត្តករណីសិក្សាពីរផ្សេងទៀត នៅតំបន់វាលទំនាប និងតំបន់នេសាទទឹកសាប ។

# II
# វិធីសាស្ត្រស្រាវជ្រាវ

## ២.១ ការជ្រើសរើសទីតាំង

ដូចបានបញ្ជាក់រួចហើយ យើងបានកំណត់យកខេត្តកំពត និងខេត្តក្រចេះ សម្រាប់ធ្វើការសិក្សា (រូបភាព ១) និងបានជ្រើសរើសតំបន់សិក្សា ដូចក្នុងជុំទី៣នៃការសិក្សាពីការចាកផុតពីភាពក្រីក្ររបស់ វបសអ។ ទីតាំងភូមិជាក់លាក់មានដូចតទៅ៖

- ភូមិកញ្ជរ នៅខេត្តក្រចេះ ដោយសារមានការពឹងផ្អែកខ្លាំងលើធនធានព្រៃឈើ និង
- ភូមិកំពង់ត្នោត ក្នុងខេត្តកំពត ដោយសារមានការពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីសមុទ្រ (ការនេសាទតាមឆ្នេរ និងស្រែអំបិល)។

រូបភាព ១៖ ផែនទីបង្ហាញទីតាំងសិក្សា



## ២.២ ក្រុមស្រាវជ្រាវ

### ២.២.១ អ្នកចុះអង្កេត

ក្រុមអ្នកស្រាវជ្រាវ មានបទពិសោធន៍គ្រប់គ្រាន់ផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសក្នុងវិស័យព្រៃឈើ។ ក្រុមនេះបានចុះសិក្សាដល់កន្លែងជាច្រើន និងកសាងទំនាក់ទំនងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានក្នុងទីតាំងសិក្សា។ អ្នកចុះអង្កេតត្រូវបានជ្រើសរើសដោយប្រយ័ត្នប្រយែង និងណែនាំឲ្យចេះគ្រប់គ្រងការងារអង្កេតគ្រួសារ ហើយភាគច្រើនជានិស្សិតឆ្នាំទី៣ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ក្នុងជំនាញធនធានធម្មជាតិ និងបរិស្ថាន និងនិស្សិតបញ្ចប់ការសិក្សាខាងព្រៃឈើ ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ អ្នកទាំងនេះធ្លាប់បានចូលរួមក្នុងការសិក្សាដល់កន្លែងពីមុនៗរបស់ វបសអ និងមានសមត្ថភាពខ្ពស់ បទពិសោធន៍ និងចំណេះដឹងគ្រប់គ្រាន់ ក្នុងការធ្វើសម្ភាសន៍គ្រួសារដើម្បីទទួលបានទិន្នន័យ និងព័ត៌មានប្រកបដោយគុណភាព។

ជំនួយការនៅមូលដ្ឋាន ក៏បានសហការក្នុងអំឡុងពេលធ្វើអង្កេតដល់កន្លែង ដើម្បីជួយក្រុមអ្នកស្រាវជ្រាវដែរ ប៉ុន្តែមិនអនុញ្ញាតឲ្យចុះជាប់ជាមួយក្រុមស្រាវជ្រាវក្នុងពេលធ្វើសម្ភាសន៍ទេ ដើម្បីរក្សាគុណភាពព័ត៌មាន និងផ្តល់សេរីភាពឲ្យគ្រួសារនានាអាចឆ្លើយសម្ភាសន៍ផ្តល់ព័ត៌មានដល់ក្រុមស្រាវជ្រាវ។

### ២.២.២ គ្រួសារគំរូតាង

គ្រួសារគំរូតាងសរុប ៨០គ្រួសារ ត្រូវបានជ្រើសរើស ក្នុងភូមិកំពង់ត្នោត និងភូមិកញ្ជរ។ យើងបានជ្រើសរើសភូមិទាំងពីរនេះ ដើម្បីសិក្សាពីការប្រែប្រួលនៃប្រាក់ចំណូលដែលផ្អែកលើធនធានសមុទ្រក្នុងខេត្តកំពត និងប្រាក់ចំណូលផ្អែកលើធនធានព្រៃឈើនៅតំបន់ខ្ពង់រាបក្នុងខេត្តក្រចេះភាគឦសាន។ របាយគ្រួសារឆ្លើយសម្ភាសន៍ក្នុងភូមិសិក្សានេះ មានបង្ហាញក្នុងតារាង ១។

តារាង ១៖ ក្របខ័ណ្ឌគំរូតាងសំរាប់ខេត្ត ភូមិ និងគ្រួសារត្រូវចុះសិក្សា

| ខេត្ត | ស្រុក | ចំនួនភូមិសិក្សា | ចំនួនគ្រួសារគំរូតាង | ចំនួនគ្រួសារ ក្នុងភូមិនីមួយៗ[a] |
|---|---|---|---|---|
| កំពត | កំពត | 1 | 40 | 363 |
| ក្រចេះ | ឆ្លូង | 1 | 40 | 267 |
| សរុប | | 2 | 80 | 630 |

[a] ចំនួនគ្រួសារក្នុងភូមិនីមួយៗ បានជ្រើសរើសយកចេញពីការសិក្សារបស់ Fitzgerald and So, 2007

### ២.២.៣ ការរៀបចំ និងការបកប្រែបញ្ជីសំណួរ

បញ្ជីសំណួរ បានរៀបចំឡើងដោយអនុលោមតាមពិធីសារស្រាវជ្រាវរួមគ្នា រវាង វបសអ និង SEI និងបកប្រែជាភាសាខ្មែរដោយក្រុមស្រាវជ្រាវមុនពេលធ្វើតេស្តសាកល្បង។ ប្រជាជននៅទីតាំងសិក្សានិយាយភាសាខ្មែរទាំងអស់គ្នា។ បញ្ជីសំណួរបានរៀបចំឡើងដោយប្រើភាសាសាមញ្ញ ច្បាស់លាស់ និងងាយយល់ ដើម្បីផ្តល់ភាពងាយស្រួលដល់ក្រុមស្រាវជ្រាវ និងគ្រួសារឆ្លើយសម្ភាសន៍។

## ២.៣ ការងារចុះដល់កន្លែង

ក្រុមចុះអង្កេតត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការងារចុះដល់កន្លែង៖ ១) បណ្តុះបណ្តាលក្រុមចុះដល់កន្លែងពីរបៀបពន្យល់អត្ថន័យបញ្ជីសំណួរ ២) ជូនដំណឹងថ្នាក់ដឹកនាំសហគមន៍នៅតាមភូមិជ្រើសរើសអំពីគោលបំណងនៃការ

សិក្សា និងថ្ងៃស្នើចុះសិក្សានៅទីនោះ ៣) ធ្វើតេស្តបញ្ជីសំណួរជាមុនជាមួយ ២-៣គ្រួសារក្នុងភូមិជ្រើសរើស ៤) ធ្វើការពិភាក្សាក្រុមស្នូលលើកទី១ ជាមួយសហគមន៍ដើម្បីគូសផែនទីភូមិសាស្ត្រ និងធនធានប្រើប្រាស់នៅមូលដ្ឋាន ៥) ធ្វើសម្ភាសន៍គ្រួសារដែលបានជ្រើសរើស ៦) ធ្វើការពិភាក្សាក្រុមស្នូលលើកទី២ ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីផ្ទៀងផ្ទាត់ និងផ្តល់សុពលភាពលើទិន្នន័យ និងព័ត៌មានទទួលបានពីការពិភាក្សាក្រុមស្នូលលើកទី១ ជាមួយសហគមន៍ ៧) ធ្វើការពិភាក្សាក្រុមស្នូលលើកទី៣ ជាមួយគ្រួសារឆ្លើយសម្ភាសន៍ ដើម្បីផ្ទៀងផ្ទាត់ និងផ្តល់សុពលភាពដល់ទិន្នន័យ និងព័ត៌មានទទួលបានក្នុងពេលធ្វើសម្ភាសន៍គ្រួសារ។

### ២.៣.១ ការពិភាក្សាក្រុមស្នូល

ការពិភាក្សាក្រុមស្នូលចំនួន៣ (FGDs) បានអនុវត្តឡើង ដែលក្នុងនោះ មាន ២ FGDs ធ្វើនៅខេត្តក្រចេះ និង ១នៅខេត្តកំពត។ លើកទី១ បានធ្វើឡើងជាមួយថ្នាក់ដឹកនាំសហគមន៍ ដើម្បីផ្ទៀងផ្ទាត់ពីផែនទីធនធាន ដែលគូសដោយក្រុមសិក្សាក្នុងគម្រោង MOPS។ ការពិភាក្សាក្រុមស្នូលលើកទី២ បានធ្វើឡើងជាមួយ អាជ្ញាធរមូលដ្ឋាន ដើម្បីផ្ទៀងផ្ទាត់ និងផ្តល់សុពលភាព ដល់ទិន្នន័យ និងព័ត៌មានទទួលបានក្នុងការពិភាក្សាក្រុមស្នូលលើកទី១ ជាមួយសហគមន៍។ ការពិភាក្សាក្រុមស្នូលចុងក្រោយ បានធ្វើឡើងជាមួយ គ្រួសារឆ្លើយសម្ភាសន៍ ដើម្បីផ្ទៀងផ្ទាត់ និងផ្តល់សុពលភាពដល់ទិន្នន័យ និងព័ត៌មានទទួលបានក្នុងអំឡុងពេលអង្កេត។

### ២.៣.២ ការធ្វើសម្ភាសន៍គ្រួសារ

បញ្ជីសំណួរអង្កេតគ្រួសារ ចែកចេញជា ៣ផ្នែក៖ ១) ព័ត៌មានទូទៅអំពីអ្នកឆ្លើយសម្ភាសន៍ ២) សំណួរផ្អែកលើដ្យាក្រាមនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីផ្នែកផ្គត់ផ្គង់ និងវប្បធម៌ (provisioning and cultural ecosystem services) ៣) សំណួរផ្អែកលើដ្យាក្រាមនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី។

# III
# លទ្ធផលស្រាវជ្រាវ

## ៣.១ ការពិពណ៌នាពីតំបន់សិក្សា

ភូមិកំពង់ត្នោត ស្ថិតក្នុងស្រុកកំពត នៅចម្ងាយ ៣គីឡូម៉ែត្រពីផ្លូវជាតិ និងមានប្រជាជនសរុប ២១៥០នាក់ ត្រូវជា ៣៦៣គ្រួសារ (តារាង ២)។ ការនេសាទ ជាប្រភពចំណូលចម្បងសម្រាប់អ្នកភូមិភាគច្រើន។ ភូមិនេះមានព្រៃកោងកាងប្រមាណ ៧០,៤១ហិកតា។ នៅឆ្នាំ២០០៧ Fitzgerald និង So បានកត់សម្គាល់ថា អ្នកភូមិធ្វើស្រូវវស្សា ចាប់ពីចុងខែកក្កដា ដល់ខែមករា ប៉ុន្តែដោយសារដីមិនសូវល្អ ការខូចខាតដោយសារទឹកសមុទ្រឡើងកម្ពស់ ហើយជ្រាបចូល និងកង្វះបច្ចេកទេសកសិកម្មសម្រាប់ការដាំដុះបែបទំនើប ធ្វើឲ្យទិន្នផល មានកម្រិតទាបត្រឹម ០,៩តោន/ហិកតា។ គ្រួសារប្រមាណ ៤០% ដាំដំណាំលក់យកប្រាក់ ហើយ ២០% ទៀតខ្វះដីដាំដុះ។ ប្រជាជនភាគច្រើន ធ្វើនេសាទ និងប្រមូលផលិតផល និងសត្វសមុទ្រ ប៉ុន្តែការនេសាទខុសច្បាប់បានកើនឡើង មួយផ្នែកដោយសារកំណើនតម្រូវការសត្វសមុទ្រតូចៗ និងការថយចុះធនធានទ្រព្យរួម (CPR) និងបរិមាណប្រភេទត្រីនីមួយៗដែលមាន (ស្តុកត្រី)។ ស្រែអំបិលជាប្រភពការងារសំខាន់មួយ ជាពិសេសសម្រាប់ស្ត្រី។ ផ្លូវគមនាគមន៍ ត្រូវបានជួសជុលឲ្យល្អឡើងក្នុងឆ្នាំ២០០៣ ដំណាលគ្នានឹងការកសាងផ្លូវជាតិ។ សាលារៀនមួយបានសាងសង់តាំងពីឆ្នាំ១៩៩៨ ហើយផ្តល់ការអប់រំកម្រិតបឋមដល់សិស្ស។ មានគ្រូពេទ្យឯកជននៅក្នុងភូមិ និងមានមណ្ឌលសុខភាពមួយដែរនៅក្នុងឃុំ។ អ្នកភូមិត្រូវធ្វើដំណើរទៅក្រុងកំពតនៅពេលមានជម្ងឺធ្ងន់។

ភូមិកញ្ជរ ស្ថិតក្នុងស្រុកឆ្លូង និងមានប្រជាជនសរុប ១១០៧នាក់ ត្រូវជា ២៦៧គ្រួសារ។ ភូមិនេះ មានដីកសិកម្មតិចជាងភូមិឯទៀតក្នុងឃុំកញ្ជរ។ ការកាប់ឈើព្រៃ និងការប្រមូល CPR គឺជាប្រភពចំណូលសំខាន់ ប៉ុន្តែប្រភពទាំងពីរនេះបានថយចុះ ដោយសារការធ្វើអាជីវកម្មខ្លាំងហួសហេតុក្នុង ១០ឆ្នាំចុងក្រោយនេះ។ គ្រួសារក្នុងភូមិ ដាំទាំងស្រូវវស្សា និងស្រូវប្រាំង ហើយអាចទទួលបានទិន្នផលស្រូវពី ២,៥ ទៅ ៣តោន/ហិកតា ដោយមិនបាច់ប្រើជីគីមី។ គ្រួសារប្រហែល ២៥% គ្មានដីកសិកម្មទេ។ គ្រួសារខ្លះបានចិញ្ចឹមសត្វ និងរកចំណូលដោយការនេសាទផងដែរ ប៉ុន្តែផលត្រីបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងទសវត្សរ៍កន្លងទៅ ដោយសារការនេសាទខុសច្បាប់។ អ្នកភូមិមួយចំនួន (ក្នុងខេត្តក្រចេះ) ធ្វើចំណាកស្រុកទៅប៉ោយប៉ែត និងទៅទីក្រុងភ្នំពេញដើម្បីរកការងារធ្វើ។ ក្រោយជម្លោះប្រដាប់អាវុធបានបញ្ចប់ក្នុងឆ្នាំ១៩៩៨ សន្តិសុខនៅភូមិកញ្ជរបានល្អប្រសើរឡើង។ ផ្លូវតភ្ជាប់ពីកញ្ជរ ទៅទីតំបន់ទីប្រជុំជនក្នុងខេត្តក្រចេះ បានសាងសង់ក្នុងឆ្នាំ២០០២ ប៉ុន្តែវាបានខូចខាតទៅវិញដោយសាររថយន្តដឹកឈើធ្ងន់ៗបើកឆ្លងកាត់។ សាលាបឋមសិក្សា និងមធ្យមសិក្សា ស្ថិតនៅឯឃុំកញ្ជរ ចំងាយប្រហែល ២-៣គីឡូម៉ែត្រពីភូមិ ហើយក្មេងៗមួយចំនួននៅភូមិកញ្ជរ អាចទៅរៀននៅវិទ្យាល័យមួយចំងាយ ប្រហែល ១០គីឡូម៉ែត្រពីភូមិ។ នៅឯឃុំកញ្ជរ មានមណ្ឌលសុខភាពមួយ ប៉ុន្តែជារឿយៗប្រជាជនប្រើសេវាកម្មគ្រូពេទ្យឯកជន ឬគ្លីនិកឯកជនក្នុងមូលដ្ឋាន (Fitzgerald and So 2007)។

តារាង ២៖ លក្ខណៈសំគាល់នៃភូមិចុះអង្កេត

| ភូមិ | ស្រុក | ខេត្ត | មូលហេតុនៃការជ្រើសរើស | គ្រួសារ | ផ្លូវធ្វើដំណើរ |
|---|---|---|---|---|---|
| កំពង់ត្នោត | កំពត | កំពត | នេសាទតាមឆ្នេរ និងស្រែអំបិល | 363 | ជិតផ្លូវជាតិនៅចន្លោះក្រុងកែប និងខេត្តកំពត |
| កញ្ជរ | ឆ្លូង | ក្រចេះ | ពឹងផ្អែកខ្លាំងលើព្រៃឈើ | 267 | ផ្លូវបានកែលម្អតាំងពីឆ្នាំ២០០២ |

ប្រភព៖ *Fitzgerald and So 2007*

តារាង៣ បង្ហាញថា ចំនួនសរុបនៃគ្រួសារដែលមានជីវភាពធូរធារក្នុងភូមិកំពង់ត្នោត បានធ្លាក់ចុះពី ២៩ មកត្រឹម ២គ្រួសារ ក្នុងចន្លោះឆ្នាំ២០០៤ និង ២០០៨។ តួលេខនេះបង្ហាញពីការធ្លាក់ចុះនៃលក្ខខណ្ឌរស់នៅរបស់ប្រជាជនមូលដ្ឋានក្នុងភូមិនេះ ធៀបនឹងប្រជាជនក្នុងភូមិកញ្ជរ។ ស្ថិតិបានបង្ហាញថា គ្រួសារក្រីក្រក្នុងភូមិសិក្សាទាំង២ ត្រូវពឹងផ្អែកកាន់តែខ្លាំងលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់ជីវភាពរស់នៅរបស់ខ្លួន ហើយគ្រួសារដែលធូរធារ ក៏ទំនងត្រូវពឹងផ្អែកដូច្នេះដែរ។

តារាង ៣៖ កម្រិតសារៈសំខាន់នៃ CPR/សេវាកម្មប្រព័ន្ធអេកូឡូស៊ី[a] កំណត់ដោយបណ្តាគ្រួសារបានសិក្សា

| កម្រិតភាពក្រីក្រ | កម្រិតសារៈសំខាន់នៃ CPR | | | | |
|---|---|---|---|---|---|
| | សំខាន់ណាស់ | សំខាន់ | មិនសូវសំខាន់ | មិនដឹង | សរុប[b] |
| *កំពង់ត្នោត (២០០៤)*[c] | | | | | |
| ក្រីក្រ | 1 | 0 | 0 | 0 | 1 |
| មធ្យម | 7 | 0 | 0 | 0 | 7 |
| ធូរធារ | 25 | 3 | 1 | 0 | 29 |
| សរុប | 33 | 3 | 1 | 0 | 37 |
| *កញ្ជរ (២០០៤)*[c] | | | | | |
| ក្រីក្រ | 3 | 6 | 3 | 0 | 12 |
| មធ្យម | 7 | 5 | 5 | 0 | 17 |
| ធូរធារ | 2 | 3 | 0 | 1 | 6 |
| សរុប | 12 | 14 | 8 | 1 | 35 |
| *កំពង់ត្នោត (២០០៨)*[d] | | | | | |
| ក្រីក្រ | 17 | 0 | 0 | 0 | 17 |
| មធ្យម | 17 | 3 | 0 | 0 | 20 |
| ធូរធារ | 1 | 0 | 1 | 0 | 2 |
| សរុប | 35 | 3 | 1 | 0 | 39 |
| *កញ្ជរ (២០០៤)*[d] | | | | | |
| ក្រីក្រ | 5 | 4 | 3 | 1 | 13 |
| មធ្យម | 7 | 9 | 7 | 0 | 23 |
| ធូរធារ | 2 | 2 | 0 | 0 | 4 |
| សរុប | 14 | 15 | 10 | 1 | 40 |

[a] CPR និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីមានអត្ថន័យដូចគ្នា។ ករណីសិក្សានៅកម្ពុជា របស់ SEI-វបសអ នេះ មិនបានសួរក្រុមគ្រួសារអំពីសារៈសំខាន់ផ្សេងៗនៃ CPR និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីទេ។

[b] ចំនួនគ្រួសារសរុបក្នុងឆ្នាំ២០០៤ និង ២០០៨ ខុសគ្នាដោយសារគ្រួសារខ្លះរកមិនឃើញក្នុងឆ្នាំ២០០៤។

[c] ទិន្នន័យទទួលបានពីកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD) របស់ វបសអ ឆ្នាំ២០០៤។

[d] ទិន្នន័យទទួលបានពីកម្មវិធី PARD របស់ វបសអ ឆ្នាំ២០០៨។ ការកំណត់ក្រុមក្រីក្រក្នុងឆ្នាំ២០០៨ ផ្អែកលើការធ្វើចំណាត់ថ្នាក់កម្រិតទ្រព្យសម្បត្តិដែលបានអនុវត្តក្នុងឆ្នាំនោះដែរ។

## ៣.២ ប្រភពចំណូល

អ្នកឆ្លើយសម្ភាសន៍ ត្រូវបានស្នើឲ្យដាក់ចំណាត់ថ្នាក់ប្រភពចំណូលរបស់ខ្លួន (ប្រភពចំណូលបឋម បន្ទាប់បន្សំទី២ និង ទី៣)។រូបភាព ២ បង្ហាញពីប្រភពចំណូលចម្បងក្នុងភូមិទាំងពីរ។ នៅភូមិកំពង់ត្នោត ៦០% នៃគ្រួសារឆ្លើយសម្ភាសន៍បានប្រាប់ថា ការនេសាទតាមសមុទ្រជាប្រភពចំណូលចម្បង ហើយការធ្វើស្រែអំបិលជាប្រភពបន្ថែម។ អ្នកចូលរួម FGD ប្រាប់ថា នៅភូមិនេះ អ្នកមានស្រែអំបិល មាន ៣នាក់។ ពួកគេបញ្ជាក់ដែរថា ប្រភពចំណូលពីធនធានសមុទ្របានធ្លាក់ចុះដោយសារកំណើនចំនួនអ្នកនេសាទប្រើឧបករណ៍ខុសច្បាប់ ដូចជា សំណាញ់ក្រឡាញឹកជាដើម។ ប្រការនេះ បាននាំឲ្យ

ប្រជានេសាទត្រូវធ្វើដំណើរទៅសមុទ្រជ្រៅកាន់តែឆ្ងាយទៅៗដើម្បីប្រមូលធនធាន ហើយត្រូវប្រឈមមុខនឹងគ្រោះថ្នាក់នៃរលក និងព្យុះធំៗ។ ប្រជានេសាទមួយចំនួន និយាយថា ខ្លួនបានប្តូរមុខរបរ ដោយសារការចាប់ត្រីបានតិច នាំឲ្យប្រាក់ចំណូលថយចុះ។

រូបភាព ២៖ ប្រភពចំណូលបឋមរបស់គ្រួសារ (ជាភាគរយ)




រូបភាព ២ បង្ហាញថា អ្នកឆ្លើយសម្ភាសន៍ ៨០% ក្នុងភូមិកញ្ជរ ពឹងផ្អែកលើការដាំដុះ (ស្រូវ និងដំណាំផ្សេងទៀត) ដែលជាប្រភពចំណូលដ៏ចម្បងមួយផងដែរ។ នៅភូមិនេះ អ្នកឆ្លើយសម្ភាសន៍បានអះអាងថា ការប្រមូលធនធានព្រៃឈើ (ពិសេសអនុផលព្រៃឈើ) ជាសកម្មភាពដ៏សំខាន់មួយ ព្រោះវាជួយបំពេញបន្ថែមពីលើចំណូលទទួលបានពីការងារស្រែចំការ។ គ្រួសារភាគច្រើនក្នុងភូមិកញ្ជរ បេះប្រមូលអាហារព្រៃបានថែមទៀត (រូបភាព ៣)។ អាហារព្រៃទាំងអស់នេះ ប្រមូលបាននៅតាមវាលស្រែ និងចំការ និងកន្លែងផ្សេងទៀតក្រៅពីតំបន់ព្រៃ។

រូបភាព ៣៖ ប្រភពចំណូលទី២ ក្នុងគ្រួសារ (ភាគរយ)




## ៣.៣ ប្រភេទធនធាន

អ្នកឆ្លើយសម្ភាសន៍ ត្រូវបានស្នើឲ្យបញ្ជាក់ពីប្រភេទធនធានដែលខ្លួនបានប្រមូល និងប្រើប្រាស់។ ក្នុងនេះ គ្រួសារក្នុងការសិក្សា ពឹងផ្អែកជាចម្បងលើ ផលដំណាំ សត្វចិញ្ចឹម ឋាមពលជីវម៉ាស ការនេសាទទឹកសាប និងតាមសមុទ្រ ការប្រមូលផលព្រៃឈើ និងផ្តៅ/វល្លិ៍ ហើយបន្ទាប់មកទៀតគឺ ទឹកភ្លៀង និងទឹកលើដី ព្រមទាំងផលនេសាទ (រូបភាព ៤)។ វារីវប្បកម្មមិនទាន់មានអនុវត្តក្នុងភូមិសិក្សាទេ។ នៅភូមិកញ្ជរ មានគ្រួសារឆ្លើយសម្ភាសន៍តែ ០,៣% ប៉ុណ្ណោះ ដែលប្រាប់ថា ពួកគេប្រើទឹកក្រោមដីសម្រាប់ការប្រើប្រាស់ក្នុងផ្ទះ។

រូបភាព ៤៖ របាយជាភាគរយនៃគ្រួសារសិក្សាតិតតាមការប្រមូល និងប្រើប្រាស់ធនធានផ្សេងៗ




## ៣.៤ សេវាកម្មផ្គត់ផ្គង់

### ៣.៤.១ ដំណាំ ផ្លែឈើ និងបន្លែ

អង្កេតបង្ហាញថា ការធ្វើស្រែជាសកម្មភាពចិញ្ចឹមជីវិតចម្បងសម្រាប់ប្រជាជននៅភូមិកំពង់ត្នោត និងកញ្ជរ។ ដំណាំលក់យកប្រាក់ចម្បងៗនៅភូមិកំពង់ត្នោត រួមមាន ផ្លែឈើ ដូង និងស្វាយ ហើយផ្លែឈើ បន្លែ ដំឡូងឈើ និងឪឡឹក ជាប្រភពចំណូលចម្បងនៅភូមិកញ្ជរ (រូបភាព ៥)។

រូបភាព ៥៖ ប្រភេទដំណាំ ផ្លែឈើ និងបន្លែដាំដោយប្រជាជន (របាយជាភាគរយ)




ប្រាក់ចំណូលសរុបប្រចាំគ្រួសារនៅភូមិទាំង២ នៅរដូវប្រាំង និងរដូវវស្សា ត្រូវបានយកមកគណនាដើម្បីប្រៀបធៀបប្រាក់ចំណូលតាមរដូវ (តារាង ៤)។ លទ្ធផលអង្កេតបង្ហាញថា ចំណូលមេដ្យានសរុបនៃគ្រួសារអង្កេតនៅភូមិកំពង់ត្នោតនៅរដូវវស្សា មានប្រហែល ១៤៦,៧០ដុល្លារ គឺខ្ពស់ជាងប្រាក់ចំណូលរដូវប្រាំងរបស់គ្រួសារនៅភូមិកញ្ជរដែលមានប្រហែល ៩៦,៨៣ដុល្លារ ហើយចំណូលមេដ្យានសរុបនៃគ្រួសារអង្កេតនៅរដូវប្រាំង មានកម្រិតខ្ពស់ជាងចំណូលនៅរដូវវស្សា ព្រោះគេអាចដាំដំណាំតាមរដូវ ដែលមានផលិតភាពខ្ពស់ជាងនៅរដូវប្រាំង។ ចំណែកឯ ការប្រមូលផលផ្លែឈើច្រើនតែធ្វើឡើងនៅរដូវប្រាំង។

គម្លាតស្តង់ដារសម្រាប់រដូវទាំង២ មានចំនួន២ដងច្រើនជាងតម្លៃមធ្យម (mean)។ លក្ខណៈនេះបង្ហាញថា គ្រួសារមួយចំនួនរកចំណូលបានច្រើនពីការដាំដំណាំលក់យកប្រាក់។ លទ្ធផលអង្កេត បង្ហាញថា គ្រួសារមានចំណូលខ្ពស់រកចំណូលបានច្រើនដោយសារមូលហេតុចម្បង ២៖ (១) មានដីច្រើនកន្លែង និង (២) ដាំដំណាំលក់យកប្រាក់មានតម្លៃខ្ពស់។

តារាង ៤៖ ចំណូល (ជាដុល្លារ) របស់គ្រួសារសិក្សានៅភូមិកំពង់ត្នោត និងកញ្ជរ បានពីដំណាំ ផ្លែឈើ និងបន្លែ គិតតាមរដូវ

| អថេរ | ចំនួន | មេដ្យាន | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 31 | 96.8 | 156.8 | 265.6 | 6.1 | 1513.9 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 31 | 6.9 | 17.6 | 27.6 | 0.0 | 122.2 |
| តម្លៃសុទ្ធរដូវប្រាំង | 31 | 68.5 | 139.2 | 265.0 | 1.9 | 1500.9 |
| តម្លៃសរុបរដូវវស្សា | 27 | 146.7 | 227.9 | 290.8 | 1.5 | 1301.9 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 27 | 0.0 | 32.8 | 65.8 | 0.0 | 244.5 |
| តម្លៃសុទ្ធរដូវវស្សា | 27 | 105.6 | 195.9 | 275.9 | 1.5 | 1301.9 |
| តម្លៃសរុបប្រចាំឆ្នាំ | 36 | 195.6 | 306.0 | 421.2 | 14.7 | 2314.7 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 36 | 15.9 | 39.7 | 59.4 | 0.0 | 244.5 |
| តម្លៃសរុបប្រចាំឆ្នាំ | 36 | 132.1 | 266.9 | 412.2 | 12.2 | 2240.5 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 28 | 256.4 | 692.1 | 1,222.5 | 19.5 | 5281.2 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 28 | 3.2 | 49.2 | 72.2 | 0.0 | 232.3 |
| តម្លៃសុទ្ធរដូវប្រាំង | 28 | 201.1 | 642.8 | 1,204.6 | 19.5 | 5232.3 |
| តម្លៃសរុបរដូវវស្សា | 25 | 154.0 | 341.4 | 573.5 | 6.1 | 2310.5 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 25 | 0.0 | 21.2 | 45.3 | 0.0 | 183.4 |
| តម្លៃសុទ្ធរដូវវស្សា | 25 | 144.9 | 320.3 | 553.5 | 6.1 | 2176.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 37 | 358.4 | 754.4 | 1,169.4 | 34.1 | 5672.4 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 37 | 8.9 | 51.6 | 73.8 | 0.0 | 232.3 |
| តម្លៃសរុបប្រចាំឆ្នាំ | 37 | 293.4 | 702.9 | 1,154.2 | 34.1 | 5623.5 |

## ៣.៤.២ សត្វចិញ្ចឹម និងបសុបក្សី

គោ និងជ្រូក ជាប្រភេទសត្វចិញ្ចឹមចម្បងគេ ខណៈពេលដែលមាន់ និងទា ជាបសុបក្សីចម្បងគេ ដែលប្រជាជនចិញ្ចឹមក្នុងភូមិសិក្សា (រូបភាព ៦)។ ការចិញ្ចឹមមាន់ ជាប្រភពចំណូលចម្បងសម្រាប់គ្រួសារជាច្រើននៅភូមិកំពង់ត្នោត និងភូមិកញ្ជរ។ គ្រួសារឆ្លើយសម្ភាសន៍នៅភូមិទាំង២ ប្រាប់ថា ពួកគេចិញ្ចឹមមាន់សម្រាប់លក់ និងបរិភោគ។

រូបភាព ៦៖ របាយជាភាគរយនៃគ្រួសារមានចិញ្ចឹមសត្វសម្រាប់លក់ និងបរិភោគ



លទ្ធផលអង្កេតបង្ហាញថា ចំណូលមេដ្យានសរុបប្រចាំឆ្នាំបានពីសត្វចិញ្ចឹម និងបសុបក្សីនៅភូមិកំពង់ត្នោត និងភូមិកញ្ជរ នៅរដូវប្រាំង មានកម្រិតខ្ពស់ជាងនៅរដូវវស្សា (តារាង ៥)។ ក្នុងពេលធ្វើអង្កេត អ្នកឆ្លើយសម្ភាសន៍បានប្រាប់ថា ផលិតកម្មសត្វចិញ្ចឹមបានធ្លាក់ចុះដោយសារជំងឺរាតត្បាត។ អ្នកចូលរួមការពិភាក្សាតាមក្រុមស្នូល បញ្ជាក់ប្រាប់ថា គោរបស់ខ្លួនបានកើតជំងឺកាលពីឆ្នាំមុន។

តារាង ៥៖ ចំណូលតាមរដូវ (ជាដុល្លារ) របស់គ្រួសារសិក្សា បានពីសត្វចិញ្ចឹម និងបសុបក្សី នៅភូមិកំពង់ត្នោត និងកញ្ជរ

| **អថេរ** | **ចំនួន** | **មេដ្យាន** | **មធ្យម** | **គម្លាតស្តង់ដារ** | **អប្បបរមា** | **អតិបរមា** |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 30 | 189.5 | 269.5 | 241.9 | 11.0 | 855.8 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 30 | 30.6 | 55.9 | 74.9 | 0.0 | 366.8 |
| តម្លៃសុទ្ធរដូវប្រាំង | 30 | 155.6 | 213.5 | 201.1 | 11.0 | 750.6 |
| តម្លៃសរុបរដូវវស្សា | 22 | 59.3 | 118.0 | 140.0 | 7.3 | 475.6 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 22 | 8.2 | 24.3 | 30.8 | 0.0 | 99.0 |
| តម្លៃសុទ្ធរដូវវស្សា | 22 | 42.2 | 93.7 | 123.9 | -3.3 | 440.1 |
| តម្លៃសរុបប្រចាំឆ្នាំ | 32 | 254.4 | 333.8 | 271.3 | 18.3 | 978.0 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 32 | 42.8 | 69.2 | 84.5 | 0.0 | 415.6 |
| តម្លៃសរុបប្រចាំឆ្នាំ | 32 | 203.8 | 264.6 | 226.4 | 18.3 | 795.8 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 17 | 44.0 | 365.7 | 717.9 | 13.2 | 2713.9 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 17 | 0.0 | 33.0 | 117.7 | 0.0 | 489.0 |
| តម្លៃសុទ្ធរដូវប្រាំង | 17 | 42.9 | 332.6 | 685.8 | -0.7 | 2713.9 |
| តម្លៃសរុបរដូវវស្សា | 12 | 23.8 | 61.1 | 76.4 | 11.0 | 244.5 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 12 | 0.0 | 2.8 | 6.5 | 0.0 | 18.0 |
| តម្លៃសុទ្ធរដូវវស្សា | 12 | 16.1 | 58.3 | 78.2 | 3.9 | 244.5 |
| តម្លៃសរុបប្រចាំឆ្នាំ | 17 | 76.3 | 408.8 | 713.6 | 25.7 | 2713.9 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 17 | 0.0 | 34.9 | 117.6 | 0.0 | 489.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 17 | 76.3 | 373.8 | 683.9 | 7.9 | 2713.9 |

### ៣.៤.៣ ការនេសាទ

គ្រួសារសិក្សានៅភូមិកំពង់ត្នោត ពឹងផ្អែកលើការនេសាទតាមសមុទ្រច្រើនជាងការនេសាទទឹកសាប (រូបភាព ៧)។ ចំណូលពីការនេសាទនៅភូមិកំពង់ត្នោត បានច្រើនជាងចំណូលពីការនេសាទនៅភូមិកញ្ជរ។ ចំណូលមេដ្យានសរុបប្រចាំឆ្នាំដែលគ្រួសារនៅកំពង់ត្នោតទទួលបានពីធនធានសមុទ្រគឺ ៦១០,៦៤ដុល្លារ ធៀបនឹង ៤៨,៤១ដុល្លារ សម្រាប់គ្រួសារនៅកញ្ជរ (តារាង ៦)។

ចំណូលពីការនេសាទនៅភូមិកញ្ជរ មិនមានកម្រិតខ្ពស់ទេ ហើយវារីវប្បកម្ម ក៏មិនមែនជាប្រភពចំណូលសំខាន់សម្រាប់គ្រួសារក្នុងភូមិនេះដែរ។

រូបភាព ៧៖ របាយជាភាគរយនៃគ្រួសារប្រមូលផលនេសាទ គិតតាមប្រភេទផលនេសាទ







តារាង ៦៖ ចំណូល (ដុល្លារ) បានពីការនេសាទរបស់គ្រួសារសិក្សានៅភូមិកំពង់ត្នោត និងកញ្ជរ គិតតាមរដូវ

| អថេរ | ចំនួន | មេដ្យាន | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 33 | 305.6 | 744.0 | 1,310.6 | 1.2 | 6454.8 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 33 | 22.0 | 60.4 | 104.6 | 0.0 | 528.6 |
| តម្លៃសុទ្ធរដូវប្រាំង | 33 | 278.7 | 683.6 | 1,247.3 | 0.0 | 6234.7 |
| តម្លៃសរុបរដូវវស្សា | 23 | 246.9 | 334.3 | 349.7 | 7.8 | 1640.1 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 23 | 9.8 | 27.5 | 35.6 | 0 | 112.0 |
| តម្លៃសុទ្ធរដូវវស្សា | 23 | 211.5 | 306.9 | 331.6 | 7.8 | 1548.9 |
| តម្លៃសរុបប្រចាំឆ្នាំ | 33 | 610.6 | 977.0 | 1,467.8 | 1.2 | 6454.8 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 33 | 24.5 | 79.6 | 127.1 | 0.0 | 640.6 |
| តម្លៃសរុបប្រចាំឆ្នាំ | 33 | 437.7 | 897.4 | 1,392.0 | 1.2 | 6234.7 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 15 | 22.0 | 71.2 | 129.0 | 1.5 | 456.6 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 15 | 0.0 | 2.7 | 4.3 | 0.0 | 14.7 |
| តម្លៃសុទ្ធរដូវប្រាំង | 15 | 17.1 | 68.5 | 128.7 | 1.5 | 453.3 |
| តម្លៃសរុបរដូវវស្សា | 18 | 29.3 | 104.6 | 219.7 | 2.9 | 889.2 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 18 | 0.0 | 2.0 | 5.1 | 0.0 | 17.1 |
| តម្លៃសុទ្ធរដូវវស្សា | 18 | 29.3 | 102.6 | 219.9 | 2.9 | 889.2 |
| តម្លៃសរុបប្រចាំឆ្នាំ | 21 | 48.4 | 140.5 | 260.3 | 1.5 | 890.9 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 21 | 0.0 | 3.6 | 7.5 | 0.0 | 31.8 |
| តម្លៃសរុបប្រចាំឆ្នាំ | 21 | 47.9 | 136.9 | 260.3 | 1.5 | 889.2 |

## ៣.៤.៤ អាហារព្រៃ[3]

អាហារព្រៃចម្បងដែលគ្រួសារនៅភូមិកំពង់ត្នោតប្រមូលបាន រួមមាន សិប្បីសត្វ (ដូចជា ក្តាម ខ្យង បង្កងជាដើម) (រូបភាព ៨)។ ប្រហែល ៩០% នៃអ្នកឆ្លើយសម្ភាសន៍នៅភូមិកំពង់ត្នោត ប្រមូលសិប្បីសត្វ ដើម្បីបង្កើនប្រាក់ចំណូល។ នៅភូមិកញ្ជរ គ្រួសារឆ្លើយសម្ភាសន៍បេះប្រមូល ដើម/ស្លឹកឈើដែលអាចបរិភោគបានជាអាហារ។

3 អាហារដែលកើតឡើង ឬដុះឡើងដោយឯកឯង។

រូបភាព ៨៖ របាយជាភាគរយនៃគ្រួសារបេះប្រមូលអាហារព្រៃ បែងចែកតាមប្រភេទអាហារព្រៃ




លទ្ធផលសិក្សាបង្ហាញទៀតថា ប្រជាជននៅភូមិកំពង់ឆ្នោត អាចរកចំណូលពីការប្រមូលអាហារព្រៃបានច្រើនជាងប្រជាជននៅភូមិកញ្ជរ (តារាង ៧)។ គ្រួសារសិក្សានៅភូមិកំពង់ឆ្នោត រកបានចំណូលសរុបអតិបរមា ៣១៥៤,០៣ដុល្លារ ពីការប្រមូលអាហារព្រៃនៅរដូវប្រាំង ដែលខ្ពស់ជាខ្លាំង បើធៀបនឹងចំណូល ១៦៥២,៨១ដុល្លារ នៅរដូវវស្សា។ នៅភូមិកញ្ជរ អាហារព្រៃហាក់មិនមែនជាប្រភពចំណូលសំខាន់ទេ។ តាមការសិក្សា ប្រជាជនពឹងផ្អែកលើអាហារព្រៃ មានមិនដល់ ៥០% ទេនៅភូមិនេះ។

តារាង ៧៖ ចំណូលគ្រួសារសិក្សា (ដុល្លារ) បានពីការប្រមូលអាហារព្រៃ នៅភូមិកំពង់ឆ្នោត និងកញ្ជរ គិតតាមរដូវ

| **អថេរ** | **ចំនួន** | **មេដ្យាន** | **មធ្យម** | **គម្លាតស្តង់ដារ** | **អប្បបរមា** | **អតិបរមា** |
|---|---|---|---|---|---|---|
| *កំពង់ឆ្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 23 | 36.7 | 296.2 | 724.8 | 1.3 | 3154.0 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 23 | 0.0 | 9.8 | 45.8 | 0.0 | 220.1 |
| តម្លៃសុទ្ធរដូវប្រាំង | 23 | 36.7 | 286.4 | 705.5 | 1.3 | 3154.0 |
| តម្លៃសរុបរដូវវស្សា | 19 | 15.3 | 135.7 | 375.1 | 1.8 | 1652.8 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 19 | 0.0 | 13.3 | 52.6 | 0.0 | 229.8 |
| តម្លៃសុទ្ធរដូវវស្សា | 19 | 12.8 | 122.4 | 323.9 | 1.8 | 1423.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 30 | 25.1 | 313.0 | 827.9 | 0.0 | 3423.0 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 30 | 0.0 | 15.9 | 82.0 | 0.0 | 449.9 |
| តម្លៃសរុបប្រចាំឆ្នាំ | 30 | 24.9 | 297.1 | 772.1 | 0.0 | 3178.5 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 10 | 2.1 | 11.9 | 16.5 | 0.2 | 46.9 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 10 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសុទ្ធរដូវប្រាំង | 10 | 2.1 | 11.9 | 16.5 | 0.2 | 46.9 |
| តម្លៃសរុបរដូវវស្សា | 4 | 26.2 | 30.9 | 28.6 | 2.2 | 69.0 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 4 | 0.0 | 1.7 | 3.3 | 0.0 | 6.6 |
| តម្លៃសុទ្ធរដូវវស្សា | 4 | 26.2 | 29.2 | 25.7 | 2.2 | 62.4 |
| តម្លៃសរុបប្រចាំឆ្នាំ | 10 | 3.2 | 24.2 | 30.9 | 0.2 | 78.7 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 10 | 0.0 | 0.7 | 2.1 | 0.0 | 6.6 |
| តម្លៃសរុបប្រចាំឆ្នាំ | 10 | 3.2 | 23.6 | 29.6 | 0.2 | 72.1 |

### ៣.៤.៥ ឈើព្រៃ និងផ្តៅ/វល្លិ៍

លទ្ធផលបានពី FGD បង្ហាញថា ការប្រមូលធនធានព្រៃឈើនៅភូមិកំពង់ត្នោត បានធ្លាក់ចុះចាប់តាំងពីរដ្ឋាភិបាលបានចេញសេចក្តីសម្រេចផ្តល់សម្បទានព្រៃឈើមក។ អ្នកចូលរួម FGD និយាយថា គេមិនអនុញ្ញាតឲ្យប្រជាជនប្រមូលអនុផលព្រៃឈើ (NTFP) និងឈើឧសក្នុងតំបន់ជាកម្មសិទ្ធិរបស់ក្រុមហ៊ុនដីព្រៃសម្បទានទេ។ ប្រជាជនត្រូវបង់ប្រហែល ៦០.០០០រៀល លើ NTFP និងឧសរកបានក្នុងតំបន់របស់ក្រុមហ៊ុនសម្បទានចំនួនមួយត្រាក់ទ័រធុនតូច ឬមួយរទេះគោ ដែលជាចំណាយមួយខ្ពស់ណាស់ចំពោះប្រជាជនក្រីក្រក្នុងមូលដ្ឋាន។ ប្រជាជនត្រូវធ្វើដំណើរយ៉ាងឆ្ងាយពីភូមិរបស់ខ្លួន (ប្រហែល ១៥ ទៅ ៤០គីឡូម៉ែត្រ) ប្រសិនបើចង់ប្រមូល NTFP ដើម្បីបង្កើនចំណូល។

អ្នកភូមិនៅតែបន្តសកម្មភាពកាប់ឈើ នៅអំឡុងពេលធ្វើអង្កេត។ អ្នកចូលរួម FGD ប្រាប់ថា មានរណារត្រង់សុនីរប្រហែល ៨០គ្រឿង ដែលគេបានប្រើប្រាស់សម្រាប់កាប់ឈើក្នុងឆ្នាំ២០០៣ ហើយនៅពេលធ្វើអង្កេតនេះ នៅមានរណាជាង ២០គ្រឿង កំពុងប្រើប្រាស់នៅឡើយ។ ការកាប់ឈើក្នុងតំបន់ដីសម្បទានព្រៃឈើ នៅតែបន្តយ៉ាងសកម្មរហូតមកទល់សព្វថ្ងៃ។

រូបភាព ៩ បង្ហាញថា ប្រហែល ៥៣% នៃធនធានព្រៃឈើដែលប្រមូលបានក្នុងភូមិកញ្ជរ គឺជាឈើថ្មែរួច (ឧទាហរណ៍ ឈើអារ) ធៀបនឹងត្រឹម ១៥% នៅភូមិកំពង់ត្នោត។ គ្រួសារសិក្សានៅភូមិកញ្ជរ ក៏បានប្រមូលធនធានព្រៃឈើផ្សេងទៀតដែរ (ដូចជា ឫស្សី ផ្តៅ និងឈើ) ដើម្បីបង្កើនប្រាក់ចំណូល។ តួលេខនេះបញ្ជាក់ថា ប្រជាជននៅភូមិកញ្ជរពឹងផ្អែកលើធនធានព្រៃឈើច្រើនជាងប្រជាជនភូមិកំពង់ត្នោត។

រូបភាព ៩៖ របាយជាភាគរយនៃគ្រួសារប្រមូលផលព្រៃឈើ និងផ្តៅ/វល្លិ៍




ចំណូលសរុបអតិបរមាប្រចាំឆ្នាំរបស់គ្រួសារអង្កេតនៅភូមិកញ្ជរ បានពីការប្រមូលផលព្រៃឈើ និងផ្តៅ/វល្លិ៍ គឺ ៣១.៧៨៤,៨៤ដុល្លារ ដែលបញ្ជាក់ថា ផលិតផលឈើ និងផ្តៅ/វល្លិ៍ ជាប្រភពចំណូលចម្បងរបស់ពួកគេ (តារាង ៨)។ តួលេខនេះខ្ពស់ជាខ្លាំង បើធៀបនឹងចំណូលសរុបអតិបរមាប្រចាំឆ្នាំរកបានដោយគ្រួសារអង្កេតនៅភូមិកំពង់ត្នោត (១៧,១១ដុល្លារ) ដែលបញ្ជាក់ថា អ្នកភូមិកំពង់ត្នោតមិនពឹងផ្អែកជាចម្បងទៅលើផលិតផលឈើ និងផ្តៅ/វល្លិ៍ ទេ។

តារាង ៨៖ ចំណូលរបស់គ្រួសារសិក្សា (ជាដុល្លារ) នៅភូមិកំពង់ត្នោត និងកញ្ជរ បានពីផលិតផលឈើ និងផ្តៅ/វល្លិ៍ គិតតាមរដូវ

| **អថេរ** | **ចំនួន** | **មេដ្យាន** | **មធ្យម** | **គម្លាតស្តង់ដារ** | **អប្បបរមា** | **អតិបរមា** |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 7 | 8.1 | 7.0 | 5.6 | 0.2 | 15.8 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 7 | 0.0 | 0.4 | 0.9 | 0.0 | 2.4 |
| តម្លៃសុទ្ធរដូវប្រាំង | 7 | 5.6 | 6.6 | 5.6 | 0.2 | 15.8 |
| តម្លៃសរុបរដូវវស្សា | 4 | 5.1 | 6.9 | 8.1 | 0.2 | 17.1 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសុទ្ធរដូវវស្សា | 4 | 5.1 | 6.9 | 8.1 | 0.2 | 17.1 |
| តម្លៃសរុបប្រចាំឆ្នាំ | 9 | 9.8 | 8.5 | 5.8 | 0.3 | 17.1 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 9 | 0.0 | 0.3 | 0.8 | 0.0 | 2.4 |
| តម្លៃសរុបប្រចាំឆ្នាំ | 9 | 9.8 | 8.2 | 5.9 | 0.3 | 17.1 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 27 | 792.2 | 2567.2 | 5599.0 | 12.0 | 28,606.4 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 27 | 44.0 | 287.8 | 750.3 | 0.0 | 3423.0 |
| តម្លៃសុទ្ធរដូវប្រាំង | 27 | 660.2 | 2269.2 | 5427.9 | 11.7 | 28,117.4 |
| តម្លៃសរុបរដូវវស្សា | 16 | 465.2 | 1308.9 | 1733.5 | 8.6 | 5550.1 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 16 | 1.2 | 232.9 | 619.8 | 0.0 | 2445.0 |
| តម្លៃសុទ្ធរដូវវស្សា | 16 | 257.3 | 1076.0 | 1610.7 | 8.6 | 5501.2 |
| តម្លៃសរុបប្រចាំឆ្នាំ | 28 | 978.0 | 3202.9 | 6308.1 | 12.0 | 31,784.8 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 28 | 46.5 | 410.6 | 1196.7 | 0.0 | 5868.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 28 | 929.6 | 2811.7 | 6014.7 | 12.0 | 31,295.8 |

### ៣.៤.៦ ឱសថបុរាណធម្មជាតិ

លទ្ធផលអង្កេតបង្ហាញថា គ្រួសារសិក្សាបានប្រមូលរុក្ខជាតិផ្សេងៗ ទឹកឃ្មុំ និងដើមរុក្ខជាតិ មកធ្វើជាឱសថបុរាណ (រូបភាព ១០)។ នៅភូមិកញ្ជរ ៨៥% នៃរុក្ខជាតិផ្សេងៗដែលគ្រួសារអង្កេតយកពីក្នុងព្រៃ ត្រូវបានយកទៅប្រើធ្វើជាឱសថ ធៀបនឹង ៦០% នៅភូមិកំពង់ត្នោត។ នៅភូមិកញ្ជរ ចំណូលសរុបអតិបរមាដែលគ្រួសារអង្កេតទទួលបានពីធនធាននេះមាន ៤៤,០១ដុល្លារ ធៀបនឹង ២៩,៣៤ដុល្លារ នៅភូមិកំពង់ត្នោត (តារាង ៩)។ ដូច្នេះ ព្រៃឈើជាប្រភពចំណូលមួយដែលសំខាន់សម្រាប់គ្រួសារអង្កេតនៅភូមិកញ្ជរ ជាងគ្រួសារអង្កេតនៅភូមិកំពង់ត្នោត។ នៅភូមិទាំងពីរ រុក្ខជាតិប្រភេទផ្សេងៗ និងទឹកឃ្មុំ ក៏ត្រូវបានប្រជាជនប្រមូលពីព្រៃសម្រាប់លក់ដែរ។

អ្នកចូលរួម FGD រាយការណ៍ថា ប្រជាជននៅភូមិកញ្ជរ បានឈប់ប្រើប្រាស់ឱសថបុរាណហើយ ដោយសារមណ្ឌលសុខភាពក្នុងភូមិបានល្អប្រសើរឡើង។ ហេតុនេះហើយ គ្រួសារមួយចំនួនក៏បានលក់ឱសថបុរាណធម្មជាតិប្រមូលបានទៅឲ្យភូមិដទៃ។

រូបភាព ១០៖ របាយជាភាគរយនៃគ្រួសារប្រមូលឱសថបុរាណធម្មជាតិ គិតតាមប្រភេទឱសថ







តារាង ៩៖ ប្រាក់ចំណូល (ដុល្លារ) បានពីឱសថបុរាណធម្មជាតិរបស់គ្រួសារសិក្សា ក្នុងភូមិកំពង់ត្នោត និងកញ្ជរ គិតតាមរដូវ

| **អថេរ** | **ចំនួន** | **មេដ្យាន** | **មធ្យម** | **គម្លាតស្តង់ដារ** | **អប្បបរមា** | **អតិបរមា** |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 4 | 5.3 | 10.2 | 12.9 | 1.0 | 29.3 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 4 | 0.0 | 0.1 | 0.2 | 0.0 | 0.5 |
| តម្លៃសុទ្ធរដូវប្រាំង | 4 | 5.3 | 10.1 | 13.1 | 0.5 | 29.3 |
| តម្លៃសរុបរដូវវស្សា | 2 | 3.6 | 3.6 | 3.7 | 1.0 | 6.2 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសុទ្ធរដូវវស្សា | 2 | 3.6 | 3.6 | 3.7 | 1.0 | 6.2 |
| តម្លៃសរុបប្រចាំឆ្នាំ | 4 | 8.4 | 12.0 | 12.4 | 2.0 | 29.3 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 4 | 0.0 | 0.1 | 0.2 | 0.0 | 0.5 |
| តម្លៃសរុបប្រចាំឆ្នាំ | 4 | 8.4 | 11.9 | 12.5 | 1.5 | 29.3 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 15 | 2.2 | 3.8 | 5.5 | 0.1 | 22.0 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 15 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសុទ្ធរដូវប្រាំង | 15 | 2.2 | 3.8 | 5.5 | 0.1 | 22.0 |
| តម្លៃសរុបរដូវវស្សា | 10 | 2.0 | 4.7 | 6.6 | 0.5 | 22.0 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 10 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសុទ្ធរដូវវស្សា | 10 | 2.0 | 4.7 | 6.6 | 0.5 | 22.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 19 | 2.4 | 5.2 | 10.1 | 0.1 | 44.0 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 19 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 19 | 2.4 | 5.2 | 10.1 | 0.1 | 44.0 |

## ៣.៤.៧ ឈ្មោះពលជីវម៉ាស

លទ្ធផលបានពីការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម (PPA) ឆ្នាំ២០០៧ ក្នុងភូមិមានព្រៃឈើ (វបសអ ២០០៧) បង្ហាញថា ការប្រមូលឈើធ្វើឧស និងធ្យូង ជាសកម្មភាពពាក់ព័ន្ធនឹងប្រភពថាមពលពីរដ៏សំខាន់បំផុតរបស់អ្នកភូមិ។ ជាទូទៅ ប្រជាជននៅភូមិមានព្រៃឈើក្នុងតំបន់សិក្សា PPA គាត់ប្រមូលឈើធ្វើឧសសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន តែក៏មានគ្រួសារធូរធារមួយចំនួនតែងទិញឧសពីប្រជាជនក្រីក្រដែលប្រឹងបង្កើនប្រាក់ចំណូលដោយការប្រមូលឧសពីក្នុងព្រៃ។

ក្រុមចុះអង្កេត ក៏បានសាកសួរគ្រួសារក្នុងភូមិសិក្សាទាំងពីរផងដែរ អំពីការប្រមូលឧស និងឈើសម្រាប់ផលិតធ្យូង មែកឈើតូចៗ ជីអាចម៍សត្វ និងប្រភពឋាមពលជីវម៉ាសដទៃទៀត។ គ្រួសារភាគច្រើនប្រាប់ថា បានប្រមូលមែកឈើតូចៗ និងឈើសម្រាប់ឋាមពលជីវម៉ាស (រូបភាព ១១)។ គ្រួសារមួយចំនួនតូចនៅភូមិកំពង់ត្នោត និយាយថា ពួកគាត់ប្រមូលឧស និងឈើ មកផលិតធ្យូងសម្រាប់ការប្រើប្រាស់ក្នុងស្រុក។

រូបភាព ១១៖ របាយជាភាគរយនៃគ្រួសារប្រមូលឋាមពលជីវម៉ាសសម្រាប់លក់ និងប្រើប្រាស់ គិតតាមប្រភេទជីវម៉ាស




តារាង ១០៖ ចំណូល (ដុល្លារ) បានពីការប្រមូលឋាមពលជីវម៉ាស គិតតាមរដូវ

| អថេរ | ចំនួន | មេដ្យាន | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 39 | 14.7 | 29.0 | 45.7 | 0.2 | 234.7 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 39 | 0.0 | 0.1 | 0.2 | 0.0 | 0.8 |
| តម្លៃសុទ្ធរដូវប្រាំង | 39 | 14.7 | 28.9 | 45.7 | 0.2 | 234.7 |
| តម្លៃសរុបរដូវវស្សា | 36 | 13.8 | 21.9 | 23.7 | 1.5 | 110.0 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 36 | 0.0 | 0.1 | 0.5 | 0.0 | 2.4 |
| តម្លៃសុទ្ធរដូវវស្សា | 36 | 13.8 | 21.8 | 23.8 | 1.5 | 110.0 |
| តម្លៃសរុបប្រចាំឆ្នាំ | 39 | 29.3 | 49.2 | 57.9 | 1.7 | 234.7 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 39 | 0.0 | 0.2 | 0.6 | 0.0 | 3.2 |
| តម្លៃសរុបប្រចាំឆ្នាំ | 39 | 29.3 | 49.1 | 58.0 | 1.7 | 234.7 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 40 | 33.0 | 37.8 | 28.9 | 4.9 | 122.3 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 40 | 0.0 | 0.2 | 0.9 | 0.0 | 4.4 |
| តម្លៃសុទ្ធរដូវប្រាំង | 40 | 33.0 | 37.6 | 28.8 | 4.9 | 122.3 |
| តម្លៃសរុបរដូវវស្សា | 32 | 24.5 | 34.7 | 30.8 | 1.0 | 146.7 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 32 | 0.0 | 0.1 | 1.0 | 0.0 | 4.4 |
| តម្លៃសុទ្ធរដូវវស្សា | 32 | 24.5 | 34.6 | 30.8 | 1.0 | 146.7 |
| តម្លៃសរុបប្រចាំឆ្នាំ | 40 | 52.6 | 65.6 | 51.9 | 6.6 | 234.7 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 40 | 0.0 | 0.3 | 1.5 | 0.0 | 8.8 |
| តម្លៃសរុបប្រចាំឆ្នាំ | 40 | 51.7 | 65.3 | 51.9 | 6.6 | 234.7 |

គ្រួសារអង្កេតនៅភូមិកញ្ជរ រកចំណូលសុទ្ធប្រចាំឆ្នាំគិតជាមេដ្យានបាន ៥១,៧១ដុល្លារ ពីហាមពលជីវម៉ាសដែលខ្ពស់ជាខ្លាំង បើធៀបនឹងចំណូលពីប្រភពដូចគ្នារបស់គ្រួសារនៅភូមិកំពង់ត្នោត (២៩,៣៤ដុល្លារ)។ គម្លាតស្តង់ដារសម្រាប់តម្លៃសុទ្ធប្រចាំឆ្នាំនៅភូមិកំពង់ត្នោត មានតួលេខខ្ពស់ជាងតម្លៃមធ្យមបន្តិច ដែលបញ្ជាក់ថា គ្រួសារមួយចំនួនរកចំណូលពីហាមពលជីវម៉ាស បានច្រើនជាងគ្រួសារដទៃទៀត។ នៅភូមិកញ្ជរ គម្លាតស្តង់ដារសម្រាប់តម្លៃសុទ្ធប្រចាំឆ្នាំមានតួលេខតិចជាងតម្លៃមធ្យម ដែលបញ្ជាក់ថា គ្រួសារសិក្សារកចំណូលបានប្រហាក់ប្រហែលគ្នាពីហាមពលជីវម៉ាស។

### ៣.៤.៨ អាហារព្រៃផ្សេងទៀត

គ្រួសារដែលបានសិក្សា មានប្រមូលអាហារព្រៃផ្សេងទៀតជាច្រើន រួមមាន រុក្ខជាតិ និងស្លឹកឈើអាចបរិភោគបាន មើមនិងឫស ផ្លែឈើ សត្វព្រៃ សត្វល្អិត បក្សី មណ្ឌុកសត្វ ដូចជាកង្កែបគីង្គក់ ពពួកខ្ចៅខ្យង និងសត្វល្មូន ព្រមទាំងកែច្នៃអាហារព្រៃ (ឧទាហរណ៍ សាច់ជ្រូកព្រៃប្រឡាក់ហាល) និងធ្វើជ្រក់ទំពាំងទុកសម្រាប់ហូបផ្ទាល់ខ្លួន និងលក់ខ្លះទៅកាន់ទីផ្សារក្នុងតំបន់ (រូបភាព ១២ និងតារាង ១១)។ គ្រួសារសិក្សានៅភូមិទាំងពីរ ប្រាប់ថា ភាគច្រើនពួកគាត់បេះប្រមូលរុក្ខជាតិ និងស្លឹកឈើអាចហូបបាន។

តារាង ១១៖ ចំណូល(ជាដុល្លារ) របស់គ្រួសារសិក្សា បានពីការប្រមូលអាហារព្រៃផ្សេងៗ គិតតាមរដូវ

| អថេរ | ចំនួន | មេដ្យាន | មធ្យម | គម្លាតស្តង់ដារ | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|---|
| *កំពង់ត្នោត* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 18 | 3.6 | 7.3 | 15.0 | 0.2 | 66.3 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 18 | 0.0 | 0.0 | 0.0 | 0.0 | 0.2 |
| តម្លៃសុទ្ធរដូវប្រាំង | 18 | 3.6 | 7.3 | 15.0 | 0.2 | 66.3 |
| តម្លៃសរុបរដូវវស្សា | 26 | 9.2 | 17.5 | 32.3 | 0.2 | 162.6 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 26 | 0.0 | 1.0 | 2.5 | 0.0 | 9.8 |
| តម្លៃសុទ្ធរដូវវស្សា | 26 | 7.7 | 16.5 | 30.6 | 0.2 | 152.9 |
| តម្លៃសរុបប្រចាំឆ្នាំ | 28 | 10.6 | 20.9 | 32.3 | 0.7 | 162.6 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 28 | 0.0 | 0.9 | 2.4 | 0.0 | 9.8 |
| តម្លៃសរុបប្រចាំឆ្នាំ | 28 | 10.2 | 20.0 | 30.8 | 0.7 | 152.9 |
| *កញ្ជរ* | | | | | | |
| តម្លៃសរុបរដូវប្រាំង | 14 | 2.0 | 14.2 | 27.2 | 0.2 | 91.0 |
| តម្លៃបន្ទុកចំណាយរដូវប្រាំង | 14 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| តម្លៃសុទ្ធរដូវប្រាំង | 14 | 2.0 | 14.2 | 27.2 | 0.2 | 91.0 |
| តម្លៃសរុបរដូវវស្សា | 27 | 12.2 | 28.0 | 45.9 | 0.2 | 227.4 |
| តម្លៃបន្ទុកចំណាយរដូវវស្សា | 27 | 0.0 | 0.2 | 0.9 | 0.0 | 4.9 |
| តម្លៃសុទ្ធរដូវវស្សា | 27 | 12.2 | 28.0 | 45.9 | 0.2 | 227.4 |
| តម្លៃសរុបប្រចាំឆ្នាំ | 28 | 14.8 | 34.1 | 52.6 | 0.4 | 227.4 |
| តម្លៃបន្ទុកចំណាយប្រចាំឆ្នាំ | 28 | 0.0 | 0.2 | 0.9 | 0.0 | 4.9 |
| តម្លៃសរុបប្រចាំឆ្នាំ | 28 | 14.8 | 33.9 | 52.6 | 0.4 | 227.4 |

រូបភាព ១២៖ របាយជាភាគរយនៃគ្រួសារប្រមូលអាហារព្រៃផ្សេងៗសម្រាប់ការប្រើប្រាស់ និងសម្រាប់លក់ បែងចែកតាមប្រភេទអាហារ




## ៣.៤.៩ ជីកសិកម្ម

អង្កេតបង្ហាញថា គ្រួសារសិក្សាប្រើជីកំប៉ុសក្នុងស្រែរបស់ខ្លួន។ អ្នកឆ្លើយសម្ភាសន៍ប្រហែល ១៥នាក់ នៅភូមិកំពង់ត្នោត និង ១៨នាក់នៅភូមិកញ្ជរ អះអាងថា ខ្លួនប្រើជីកំប៉ុសជាចម្បងនៅក្នុងស្រែ (រូបភាព ១៣)។ ទោះយ៉ាងនេះក្តី ជីគីមីនៅតែសំខាន់សម្រាប់គ្រួសារសិក្សានានានៅភូមិកំពង់ត្នោត។

រូបភាព ១៣៖ ការប្រើប្រាស់ជីកសិកម្មតាមគ្រួសារ




## ៣.៤.១០ ទឹកសាប

នៅភូមិកញ្ជរអ្នកចូលរួម FGD រាយការណ៍ថា ទន្លេវាកាន់តែរាក់ទៅៗ ធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក។ ក្នុងអំឡុងពេលអង្កេត អ្នកឆ្លើយសម្ភាសន៍ ក៏បានលើកឡើងពីកំណើនខ្លាំងនៃស្លែ និងរុក្ខជាតិលើផ្ទៃទឹកផងដែរ។ បញ្ហាទាំងនេះហាក់ដូចជាលទ្ធផលនៃការថយចុះលំហូរទឹកទន្លេ ដែលអាចបណ្តាលមកពីការសាងសង់ទំនប់ក្នុងតំបន់ខ្សែទឹកខាងលើនៃទន្លេមេគង្គ។ ផ្ទៃដីមួយចំនួនក្នុងភូមិ តែងរងគ្រោះដោយទឹកជំនន់ក្នុងខែកក្កដា ជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ២០០៨-២០០៩ កសិករទទួលទិន្នផលស្រូវបានខ្ពស់ ព្រោះមានទឹកគ្រប់គ្រាន់សម្រាប់ការស្រោចស្រព។ គួរកត់សំគាល់ថា ភូមិកញ្ជរ ធ្លាប់ជួបរដូវប្រាំងមានរយៈពេលយូរខុសធម្មតាម្តងហើយ។

ក្រុមអង្កេតបានស្នើឲ្យអ្នកភូមិចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងការដោះស្រាយបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងពិពណ៌នាពីវិធីសម្របខ្លួនដើម្បីទប់ទល់នឹងផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត។ ប្រជាជនភាគច្រើននិយាយថា គាត់ពុំមានរៀបចំត្រៀមអ្វីសោះទេសម្រាប់ទប់ទល់នឹងហានិភ័យនេះ។ វិធានការសម្របខ្លួនជាប្រពៃណីរួមមាន ការធ្វើក្រោលនៅទីខ្ពស់សម្រាប់ដាក់សត្វចិញ្ចឹម បង្កើនស្តុកអាហារក្នុងគ្រួសារ បង្កើនស្តុកចំណីសត្វ និងរៀបចំទូកសម្រាប់ធ្វើដំណើរក្នុងពេលមានទឹកជំនន់។ គ្រួសារមួយចំនួន ធ្វើការផ្លាស់ទីទៅកន្លែងមានសុវត្ថិភាពនៅពេលដឹងថានឹងមានទឹកជំនន់។

អ្នកឆ្លើយសម្ភាសន៍ ក៏ទទួលសំណើឲ្យរាយការណ៍ប្រាប់ពីប្រភពទឹកដែលខ្លួនប្រើសម្រាប់ការសំអាតផ្សេងៗ ហូប និងចំអិនអាហារ ងូត អាជីវកម្មខ្នាតតូច ដឹកជញ្ជូនទំនិញ ស្រោចដំណាំ និងផលិតកម្មអំបិល។ ក្នុងចំណោមប្រភពទាំងបី (ទឹកភ្លៀង ទឹកក្រោមដី និង ទឹកលើដី) នៅភូមិទាំងពីរ មាន ១៦ គ្រួសារសិក្សាទាញយកទឹកក្រោមដីក្នុងបរិមាណតិចតួចសម្រាប់ការប្រើប្រាស់ក្នុងផ្ទះ (ហូប និងចំអិនអាហារ) (រូបភាព ១៤)។ នៅភូមិកំពង់ត្នោត អ្នកឆ្លើយសម្ភាសន៍ ពឹងផ្អែកលើប្រភពទឹកត្រពាំង និងទឹកភ្លៀង។ គ្រួសារមួយចំនួនប្រើប្រាស់ទឹកបូម/សប់ពីអណ្តូង នៅរដូវវស្សា។ កង្វះទឹកជាបញ្ហាចម្បងមួយនៅរដូវប្រាំង។

រូបភាព ១៤៖ ប្រភពទឹកប្រើប្រាស់ដោយគ្រួសារសិក្សាសម្រាប់គោលដៅផ្សេងៗ




## ៣.៥ សេវាកម្មវប្បធម៌

### ៣.៥.១ ទេសចរណ៍

គ្រួសារអង្កេតនៅភូមិទាំងពីរ មិនមានលទ្ធភាពរកចំណូលពីវិស័យទេសចរណ៍ទេ។ គ្មានអ្នកឆ្លើយសម្ភាសន៍ណាម្នាក់ប្រាប់ថា មានអត្ថប្រយោជន៍អ្វីពីវិស័យទេសចរណ៍ដែលអាចរួមចំណែកក្នុងប្រាក់ចំណូលរបស់គ្រួសារទេ។

## ៣.៦ និន្នាការទូទៅ

### *៣.៦.១ សេវាកម្មអេកូឡូស៊ី*

សេវាកម្មអេកូឡូស៊ី ដែលភាគច្រើនជួយរួមចំណែកដល់ចំណូលរបស់គ្រួសារក្នុងខេត្តសិក្សាទាំង២ ជាទូទៅ កំពុងមាននិន្នាការថយចុះ(រូបភាព១៥)។នៅខេត្តកំពតធនធានទាំងអស់កំពុងថយចុះដោយសារកំណើនចំនួនប្រជាជនដែលប្រមូលធនធានទាំងនេះដោយប្រើឧបករណ៍ខុសច្បាប់ (ដូចជា សំណាញ់ក្រឡាញឹក) និងអ្នកកាប់ព្រៃកោងកាងយកដីធ្វើស្រែអំបិល។ កង្វះការពង្រឹងអនុវត្តន៍ច្បាប់ ក៏រួមចំណែកបង្កើតបញ្ហានេះដែរ។ អ្នកនេសាទត្រូវទៅនេសាទឆ្ងាយៗក្នុងទឹកជ្រៅ ប្រឈមនឹងគ្រោះថ្នាក់នៃរលកសមុទ្រ និងព្យុះធំៗ។ ប្រជាជនមួយចំនួនបានផ្លាស់ប្តូរមុខរបរខ្លួន រីឯអ្នកឯទៀតនៅបន្តការងារដដែល ទោះបីវាអាចផ្តល់ចំណូលកាន់តែតិចពីមួយឆ្នាំទៅមួយឆ្នាំក្តី។

រូបភាព ១៥៖ និន្នាការរបស់គ្រួសារ ក្នុងការប្រមូលធនធានពីសេវាកម្មអេកូឡូស៊ីក្នុងតំបន់សិក្សា




*សម្គាល់៖ ១០០ ជាកម្រិតគោលនៃបរិមាណធនធានប្រមូលបានក្នុងឆ្នាំ១៩៩៩។*



នៅខេត្តក្រចេះ ការថយចុះធនធានដែលជាប្រភពចំណូលប្រចាំគ្រួសារដោយសារការរានព្រៃ និងការកាប់បំផ្លាញព្រៃឈើ ព្រមទាំងថ្លៃចូលទៅរក ឬប្រើប្រាស់ធនធាន ក្រោយពេលមានក្រុមហ៊ុនព្រៃសម្បទានមកកាន់កាប់កន្លែងនោះ បានបង្កការលំបាកដល់ជីវភាពរបស់ប្រជាជនក្នុងភូមិ។ អ្នកភូមិសង្កេតឃើញថា ធនធាននៅក្នុងភូមិសិក្សា បានធ្លាក់ចុះគួរឲ្យកត់សម្គាល់ ហើយប្រជាជនពិបាកស្វែងរកបានផលិតផលព្រៃឈើដែលពួកគេតែងពឹងផ្អែកសម្រាប់ជាអាហារ និងប្រភពចំណូលនៅក្បែរភូមិ សម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់ខ្លួន។

អ្នកចូលរួម FGD បានបញ្ជាក់យ៉ាងច្បាស់ថា ទឹកទន្លេកាន់តែរាក់ទៅៗ ហើយស្លែដែលឃើញមានជារឿយៗនៅលើផ្ទៃទឹក វាកាន់តែក្រាស់ឡើងៗ។ រឿងនេះបណ្តាលពីលំហូរទឹកទន្លេយឺតជាងមុន ដែលអាចជាលទ្ធផលនៃការសាងសង់ទំនប់ទឹកនៅទន្លេមេគង្គភាគខាងលើ។ ភូមិកញ្ជរត្រូវទឹកជន់លិចជារឿយៗ ហើយការនេសាទតាមទន្លេលែងមានទៀតហើយ ព្រោះមានប្រជាជនកាន់តែច្រើនឡើង បានស្នាក់ទឹកទន្លេនៅខេត្តកំពង់ចាម ដើម្បីនេសាទត្រីដោយប្រើឧបករណ៍ម៉ាញ់ (សំណាញ់តូចៗ)។

យោងតាមអ្នកចូលរួម FGD រដូវប្រាំងប្រែជាវែងជាងរដូវវស្សា ហើយអាកាសធាតុក៏កាន់តែក្តៅឡើង។ ប្រជាជនក្នុងភូមិគិតថា ការបាត់បង់ព្រៃឈើជាមូលហេតុធ្វើឲ្យអាកាសធាតុកាន់តែក្តៅឡើង។ ចំនួនសត្វល្អិតបំផ្លាញដំណាំបានកើនឡើងក្នុងតំបន់អង្កេត ហើយដើម្បីដោះស្រាយបញ្ហានេះ ប្រជាជនក្នុងភូមិប្រើថ្នាំបំបាត់កត្តាចង្រៃ និងថ្នាំសម្លាប់សត្វល្អិតយ៉ាងច្រើន ដោយមិនបានពិចារណាអ្វីច្រើនទេ។

ជាទូទៅ សេវាកម្មអេកូឡូស៊ីសំខាន់ៗ រួមមាន ជលផល អាហារព្រៃ ឈើ និង ផ្តៅ/វល្លិ៍ រុក្ខជាតិឱសថ ថាមពលជីវម៉ាស និង អាហារព្រៃផ្សេងទៀត បានធ្លាក់ចុះជាបណ្តើរៗក្នុងអំឡុងឆ្នាំ១៩៩៩ ដល់ ២០០៨ ដោយសារមូលហេតុដូចបានបង្ហាញខាងលើ។

### ៣.៦.២ សេវាកម្មប្រព័ន្ធអេកូឡូស៊ីជាធនធានដ៏សំខាន់

ក្នុងអំឡុងពេលធ្វើសម្ភាសន៍ដល់កន្លែងអ្នកភូមិភាគច្រើននិយាយថា ពួកគេពឹងផ្អែកជាចម្បងលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់ជីវភាព និងការរកចំណូលប្រចាំថ្ងៃរបស់ខ្លួន។ និន្នាការធ្លាក់ចុះក្នុងសេវាកម្មប្រព័ន្ធអេកូឡូស៊ីនេះបណ្តាលឲ្យថយចុះប្រាក់ចំណូល និងជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន។

រូបភាព ១៦៖ តម្លៃសុទ្ធប្រចាំឆ្នាំជាមធ្យម របស់គ្រួសារសិក្សា បានមកពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី



រូបភាព ១៦ បង្ហាញថា តម្លៃសុទ្ធប្រចាំឆ្នាំរបស់គ្រួសារសិក្សា (លេខមេដ្យាន) បានពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី គឺទទួលបានជាចម្បងពី ដំណាំ សត្វចិញ្ចឹម ឋាមពលជីវម៉ាស និងការនេសាទ ហើយបន្ទាប់មកគឺមាន ឈើ និងផ្តៅ/វល្លិ៍ ក្នុងខេត្តក្រចេះ និងអាហារព្រៃ ក្នុងខេត្តកំពត។ មានតែប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលរកបានចំណូលខ្ពស់ពីឈើ និងផ្តៅ/វល្លិ៍ ប៉ុន្តែវាលែងជាប្រភពចំណូលរយៈពេលវែងទៀតហើយ ពីព្រោះក្រុមហ៊ុនសម្បទានបានរារាំងប្រជាជនមិនឲ្យចូលទៅរកធនធានទាំងនោះទៀតទេ។

## *៣.៦.៣ កម្រិតភាពក្រីក្រ និង សេវាកម្មប្រព័ន្ធអេកូឡូស៊ី*

តារាង ១២ បង្ហាញថា ក្នុងចំណោម ៤០គ្រួសារ មានប្រហែល ៣៦គ្រួសារ ជាពិសេសគ្រួសារស្ថិតក្នុងក្រុមក្រីក្រ និងមធ្យម ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីចម្បងៗ ៥ ។ គ្រួសារក្រីក្រ និងមធ្យម ទំនងត្រូវពឹងផ្អែកខ្លាំងជាងលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីចម្បងៗទាំងអស់នេះ គឺអាចដោយសារពួកគេខ្វះលទ្ធភាពធ្វើជំនួញ ឬរកការងារអ្វីផ្សេងពីនេះ។ គ្រួសារធូរធារនៅភូមិកញ្ជរ ច្រើនពឹងផ្អែកលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី ៤ ក្នុងចំណោមសេវាកម្មចម្បងទាំង៥ រីឯនៅភូមិកំពង់ត្នោត ពួកគេពឹងផ្អែកលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី ៣ ដែលបង្ហាញថា ជីវភាពរស់នៅរបស់ពួកគេ មិនមែនសុទ្ធតែត្រូវពឹងផ្អែកលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីទាំងនោះទេ ព្រោះពួកគេមានមធ្យោបាយគ្រប់គ្រាន់ដើម្បីទិញម្ហូបអាហារប្រចាំថ្ងៃដោយមិនចាំបាច់ចូលក្នុងព្រៃ ដូចគ្រួសារក្រីក្រ និងមធ្យមដែលបានចាត់ទុកសេវាកម្ម ប្រព័ន្ធអេកូឡូស៊ីថាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្លួន។

ស្ថានភាពជនក្រីកាន់តែលំបាកឡើងពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារការថយចុះមធ្យោបាយចូលទៅប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី (ជាពិសេស ដំណាំ ផ្លែឈើនិងបន្លែ ផលនេសាទនិងផលព្រៃឈើ ឋាមពលជីវម៉ាស និង អាហារព្រៃ)។ ដូចបានកត់សំគាល់ក្នុងផ្នែកខាងលើ ស្តីពីសេវាកម្មផ្សេងៗដែលអាចរកបាន គឺថា គ្រួសារក្រីក្រមានលទ្ធភាពតិចជាងគ្រួសារធូរធារ ក្នុងការបានប្រើប្រាស់ដំណាំ ផ្លែឈើនិងបន្លែ ផលនេសាទនិងផលព្រៃឈើ ឋាមពលជីវម៉ាស និងអាហារព្រៃ ដើម្បីបង្កើតជាប្រភពចំណូលចម្បង ពីព្រោះពួកគេមានឱកាស និងមធ្យោបាយតិចតួចជាង ដើម្បីចូលទៅប្រើប្រាស់សេវាកម្មទាំងនោះ។

តារាង ១២៖ ការបែងចែកគ្រួសារសិក្សាជាក្រុម តាមកម្រិតភាពក្រីក្រ និងការពឹងផ្អែកលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីចម្បង ៤

| **កម្រិតភាពក្រីក្រ**[a] | ប្រភេទសេវាកម្មប្រព័ន្ធអេកូឡូស៊ីចម្បង។ | | | | | | |
|---|---|---|---|---|---|---|---|
| | ចំនួន[b] | អាហារព្រៃ (n=25) | ផលព្រៃឈើ (n=11) | ឋាមពលជីវម៉ាស (n=38) | ដំណាំ (n=36) | ផលនេសាទ (n=35) | សរុប (n=107) |
| *កំពង់ត្នោត* | | | | | | | |
| ក្រីក្រ | 17 | 48.0 | 45.4 | 42.1 | 36.1 | 42.9 | 42.7 |
| មធ្យម | 20 | 52.0 | 54.6 | 52.6 | 55.6 | 54.3 | 53.7 |
| ធូរធារ | 3 | 0.0 | 0.0 | 5.2 | 8.3 | 2.9 | 4.1 |
| សរុប | 40 | 17.4 | 7.5 | 26.2 | 24.3 | 24.1 | 100.0 |
| **កម្រិតភាពក្រីក្រ**[a] | ចំនួន[b] | អាហារព្រៃ (n=11) | ផលព្រៃឈើ (n=25) | ឋាមពលជីវម៉ាស (n=38) | ដំណាំ (n=38) | ផលនេសាទ (n=22) | សរុប (n=96) |
| *កញ្ជរ* | | | | | | | |
| ក្រីក្រ | 13 | 36.4 | 36.0 | 34.2 | 28.9 | 36.4 | 33.5 |
| មធ្យម | 23 | 63.6 | 56.0 | 57.9 | 60.5 | 54.6 | 58.2 |
| ធូរធារ | 4 | 0.0 | 8.0 | 7.9 | 10.5 | 9.1 | 8.2 |
| សរុប | 40 | 8.2 | 18.1 | 28.3 | 28.3 | 16.4 | 100.0 |

[a] ការបែងចែកជាក្រុមតាមកម្រិតភាពក្រីក្រ ផ្អែកលើសកម្មភាពធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិនៃកម្មវិធី PARD របស់ CDRI ឆ្នាំ២០០៨

[b] តួលេខនេះបង្ហាញពីចំនួនគ្រួសារសរុប

# IV

# សេចក្តីសន្និដ្ឋាន

លទ្ធផលស្រាវជ្រាវបង្ហាញថា សេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅតែសំខាន់សម្រាប់គ្រួសារនៅតំបន់ជនបទដែលតែងបានពឹងផ្អែកលើសេវាកម្មទាំងនោះ។ នៅភូមិកំពង់ត្នោត ធនធាននេសាទជាប្រភពចំណូលចម្បងរបស់គ្រួសារ ហើយបន្ទាប់មកមាន ជីវម៉ាស និងអាហារព្រៃ។ អ្នកភូមិដែលមានឧបករណ៍គ្រប់គ្រាន់ អាចរកប្រាក់បានច្រើនជាងអ្នកដែលមិនមាន ឬអ្នកខ្វះឧបករណ៍។ នៅកញ្ជរ អ្នកភូមិរងការប៉ះពាល់ជាញឹកញាប់ដោយទឹកជំនន់ និងគ្រោះរាំងស្ងួត។ គ្រួសារក្រីក្រជារឿយៗ មិនដឹងធ្វើយ៉ាងណាទប់ទល់នឹងផលប៉ះពាល់នៃគ្រោះធម្មជាតិទាំងនោះទេ ហើយពួកគាត់ប្រើប្រាស់យន្តការជាប្រពៃណីដើម្បីបន្ថយការប៉ះពាល់ផ្សេងៗ។ ផលប៉ះពាល់ជាក់ស្តែងនៃការប្រែប្រួលអាកាសធាតុ រួមមានទឹកជំនន់ ការប្រែប្រួលរបបទឹកនិងគុណភាពទឹក ការឡើងកំដៅ ខ្យល់បោកបក់ខ្លាំងជាងមុន រដូវប្រាំងរយៈពេលវែង រដូវវស្សាមានភាពយឺតយ៉ាវ ភ្លៀងធ្លាក់មិនទៀងទាត់ និងចំនួនសត្វល្អិតកើនឡើង ដែលអាចបង្កការថយចុះគុណភាពសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងកំណើនអត្រាភាពក្រីក្រនៅជនបទ។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាប្រឈមពិតៗមួយចំពោះប្រជាជនជនបទ ហេតុនេះក្រសួង និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ គួរប្រឹងប្រែងអនុវត្តកម្មវិធី NAPA ជាតិ ឲ្យមានប្រសិទ្ធភាពខ្ពស់។ ក្របខ័ណ្ឌ NAPA មានគោលដៅ ផ្តល់ការណែនាំអំពីការសម្របសម្រួល និងការអនុវត្តគំនិតផ្តួចផ្តើមនៃការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ តាមរយៈវិធីសាស្ត្រមានការចូលរួម និងបង្កើតជាកម្លាំងចម្រុះរួមគ្នាជាមួយនឹងកម្មវិធីខាងបរិស្ថាន និងអភិវឌ្ឍន៍នានា។ គោលដៅមួយទៀត គឺដើម្បីដោះស្រាយតម្រូវការបន្ទាន់ និងក្តីបារម្ភនានារបស់ប្រជាជនមូលដ្ឋាន សម្រាប់ការបន្សាំនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ក្នុងផ្នែកសំខាន់ៗ ដូចជា កសិកម្ម ធនធានទឹក តំបន់ឆ្នេរ និងសុខភាពប្រជាជន។

ការវិភាគផ្សេងៗបង្ហាញថា គ្រួសារក្រីក្រត្រូវពឹងផ្អែកលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី ជាពិសេសដំណាំ ផ្លែឈើ និងបន្លែ ផលនេសាទនិងផលព្រៃឈើ និងអាហារព្រៃ យកមកធ្វើជាប្រភពប្រាក់ចំណូលចម្បង ខ្លាំងជាងគ្រួសារមធ្យម និងធូរធារ (សូមមើលរូបភាព ១៥ ផងដែរ)។ នៅភូមិកញ្ជរ ឈើ និងផ្តៅ/វល្លិ៍ ជាធនធានអេកូឡូស៊ីដ៏សំខាន់ និងមានចំណែកខ្ពស់នៅក្នុងប្រាក់ចំណូលរបស់គ្រួសារសិក្សានានា ហើយបន្ទាប់មក គឺការសត្វចិញ្ចឹម។ ប៉ុន្តែរបាយការណ៍របស់អ្នកចូលរួម FGD បានបង្ហាញថា គ្រួសារក្រីក្រកំពុងជួបការលំបាកកាន់តែធ្ងន់ធ្ងរឡើង ក្នុងការចូលប្រើប្រាស់តំបន់ព្រៃឈើ ដោយសារបច្ចុប្បន្នតំបន់ទាំងនេះ បានស្ថិតក្រោមសិទ្ធិដំណើរការគ្រប់គ្រងរបស់ក្រុមហ៊ុនសម្បទាន។ ការកាប់ឈើបានប៉ះពាល់ធ្ងន់ធ្ងរដល់ NTFP ប្រមូលដោយប្រជាជនមូលដ្ឋានសំរាប់តម្រូវការប្រចាំថ្ងៃរបស់ខ្លួន ហើយសកម្មភាពនេះកំពុងបន្តក្នុងតំបន់ដីសម្បទានក្នុងអំឡុងពេលចុះអង្កេត។

រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន គួរយកចិត្តទុកដាក់ខ្លាំងថែមទៀត លើការបង្ក្រាបសកម្មភាពខុសច្បាប់ ដែលបង្កការវេចរិលធនធានធម្មជាតិ ដូចជា ការប្រើប្រាស់ឧបករណ៍បង្កការហិនហោចធនធានវារីជាតិ ការរានព្រៃ ការទន្ទ្រានយកដី និងការកាប់ឈើ។ ដោយសារតំបន់ព្រៃសម្បទានពីមុនខ្លះ បានក្លាយជាតំបន់ដីសម្បទានសេដ្ឋកិច្ចនោះ ស្ថាប័នកំណត់បទបញ្ញត្តិ និងអាជ្ញាធរមូលដ្ឋាន គួរធ្វើសកម្មភាពសមស្របឲ្យបានទៀងទាត់ (រួមទាំង វិធានការអនុវត្តច្បាប់ប្រសិនចាំបាច់) ដើម្បីតាមដានការអនុវត្តកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច។ សកម្មភាពទាំងនេះ សំដៅញ៉ាំងឲ្យក្រុមហ៊ុនសម្បទានគោរពតាមច្បាប់ព្រៃឈើ គោលនយោបាយវិស័យព្រៃឈើជាតិ អនុក្រឹត្យស្ដីពីការគ្រប់គ្រងព្រៃសម្បទាន និងអនុក្រឹត្យស្ដីពីដីសម្បទានសេដ្ឋកិច្ច។ សេចក្ដីណែនាំអនុវត្តច្បាប់ខាងលើ មិនមែនគ្រាន់តែដើម្បីបង្កើតចំណូលរដ្ឋ ខេត្ត ឬសង្កាត់ប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅបង្កើនការងារនៅតំបន់ជនបទក្នុងក្របខ័ណ្ឌនៃការពង្រឹងនិងធ្វើពិពិធកម្មឱកាសរកចិញ្ចឹមជីវិត កែលម្អសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងធនធានធម្មជាតិឲ្យបានគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើការធានាឲ្យប្រព័ន្ធអេកូឡូស៊ីមានចីរភាពសមស្របផងដែរ។

# ឯកសារយោង

CDRI (2008), Poverty, Agriculture and Rural Development Programme: *Wealth Ranking-Social and Mobility Mapping*, unpublished document (Phnom Penh: CDRI)

CDRI (2007), *Annual Development Review 2006-2007* (Phnom Penh: CDRI)

Fitzgerald, Ingrid and Sovannarith So (2007), *Moving Out of Poverty: Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI)

RGC (1993), Royal Government of Cambodia: Constitution of Cambodia 1993 (Phnom Penh: RGC)

RGC (2006), Royal Government of Cambodia: *National Adaptation Programme of Action to Climate Change (NAPA) 2006* (Phnom Penh: RGC)

RGC (2005), Royal Government of Cambodia: *National Strategic Development Plan 2006-2010* (Phnom Penh: RGC)

RGC (2005), *Sub-decree on Economic Land Concession,* No. 146 ANK/BK (Phnom Penh: RGC)

RGC (2003), Royal Government of Cambodia: *Cambodia Millennium Development Goals Report* (Phnom Penh: RGC)

RGC (2002), Royal Government of Cambodia: *Statement of the Royal Government on National Forest Sector Policy,* No. 57/SCN (Phnom Penh: RGC)

RGC (2002), Royal Government of Cambodia: *The Forestry Law,* No. NS/RKM/0802/016, 31 August 2002 (Phnom Penh: RGC)

RGC (2000), Royal Government of Cambodia: *Sub-decree on Forest Concession Management,* No. 05/ANK/BK, dated February 7, 2000 (Phnom Penh: RGC)

RGC (1998), Royal Government of Cambodia: *Cambodia National Environmental Action Plan (1998-2002)* (Phnom Penh: RGC)

TWGFE (2007), *Forest Cover Changes in Cambodia 2002-2006*, Background Paper prepared for the Cambodia Development Cooperation Forum, 19-20 June 2007 (Phnom Penh: TWGFE)

# ឧបសម្ព័ន្ធ

## ការអង្កេតគ្រួសារស្តីអំពីធនធានដែលផ្តល់ដោយប្រព័ន្ធអេកូឡូស៊ី

**គំរោង SEI**

**ព័ត៌មានត្រួតត្រួតពិនិត្យ**

| **ភារកិច្ច** | **កាលបរិច្ឆេទ** | **ដោយនរណា?** | **ស្ថានភាពជោគជ័យ? បើទេ សូមផ្តល់មូលហេតុ** |
|---|---|---|---|
| សំភាសន៍ | | | |
| ការពិនិត្យពិច័យកំរងសំណួរ | | | |
| ការចុះកូដកម្រងសំណួរ | | | |
| ការបញ្ចូលទិន្នន័យ | | | |
| ការពិនិត្យពិច័យ និងអនុម័តទិន្នន័យបញ្ចូល | | | |

I. **ព័ត៌មានទូទៅ**

1. លេខលំដាប់បញ្ជីរសំណួរ............................................... (កំណត់លេខដោយប្រធានក្រុម មុននឹងសំភាសន៍)
2. រយៈពេលសំភាសន៍: |__|__|នាទី (ចាប់ផ្តើម ..................... បញ្ចប់..............)
3. ឈ្មោះប្រធានក្រុម: លេខកូដ |__|__| ឈ្មោះ .....................
   កំណត់សំគាល់ចំពោះបញ្ជីរសំណួរនេះ ..................... ..................... ..................... ..................... .............
4. ខេត្ត: លេខកូដ |__|__| ឈ្មោះ............................... ............................... ...............................
5. ស្រុក: លេខកូដ |__|__| ឈ្មោះ............................... ............................... ...............................
6. ឃុំ: លេខកូដ |__|__| ឈ្មោះ............................... ............................... ...............................
7. ភូមិ: លេខកូដ |__|__| ឈ្មោះ............................... ............................... ...............................
8. ឈ្មោះអ្នកត្រូវបានសំភាសន៍: …………………….. ភេទ: ១=ប្រុស ២=ស្រី |__|
9. អាយុ: ____ ឆ្នាំ
10. នៅលីវ ឬ មានគ្រួសារ: ១= រៀបការ ២= នៅលីវ ៣= លែងលះ ៤= ផ្សេងៗ................................
11. ទំនាក់ទំនងទៅនឹងមេគ្រួសារ: (លេខកូដខាងក្រោម) |__|
    1= មេគ្រួសារ, 2= ប្រពន្ធ, 3= កូន, 4= ឪពុក ឬ ម្តាយ, 5= ផ្សេងៗ................................
12. កំរិតសិក្សាដែលបានបញ្ចប់………………………..
13. សមាជិកគ្រួសារ: មេគ្រួសារ……………………….. ឈ្មោះប្រពន្ធ: ……………………….
14. តើមេគ្រួសារភេទប្រុស ឬ ស្រី? ១= ប្រុស ២= ស្រី |__|

| តើនៅពេលបច្ចុប្បន្ននេះគ្រួសាររបស់អ្នកមានសមាជិកប៉ុន្មាននាក់? មិនបញ្ចូល អ្នកដែលអវត្តមាននៅក្នុងគ្រួសាររយៈពេល ៦ខែមុន(កត់ត្រាចំនួនសមាជិកគ្រួសារ) | ប្រុស | ស្រី |
|---|---|---|
| 1. សរុប | | |
| 2. វ័យក្មេង អាយុ: 0 – 14 ឆ្នាំ | | |
| 3. ពេញវ័យ អាយុ: 15-64 ឆ្នាំ | | |
| 4. វ័យចំណាស់ អាយុ: 65+ឆ្នាំ | | |

15. តើគ្រួសាររបស់អ្នកមានដីសម្រាប់ធ្វើស្រែ ចំការ និង ប្រភេទដីផ្សេងទៀតប៉ុន្មានកន្លែង?..............កន្លែង

| ដីកសិកម្ម | ទំហំសរុប (គិតជាម៉ែត្រការ៉េ) | ចំងាយពីផ្ទះ (ម៉ែត្រ) | តើដីនោះប្រើប្រាស់ដើម្បីដាំដុះផ្ទាល់ខ្លួន ឬជួលឲ្យអ្នកដទៃ? (1= ប្រើប្រាស់ផ្ទាល់ខ្លួន 2= ជួលឲ្យអ្នកដទៃ 3= ផ្សេងៗ........) |
|---|---|---|---|
| ឡូត៍ទី ១ | | | |
| ឡូត៍ទី ២ | | | |
| ឡូត៍ទី ៣ | | | |
| ឡូត៍ទី ៤ | | | |
| ឡូត៍ទី ៥ | | | |
| ឡូត៍ទី ៦ | | | |
| ប្រភេទដីផ្សេងៗទៀត (ដីផ្ទះ.............) | | | |

16. តើគ្រួសាររបស់អ្នកមានមុខរបររកទទួលទានសំខាន់ៗអ្វីខ្លះ? ចូលរៀបលំដាប់អតិបរមា ៣
១= ធ្វើស្រែចំការ ២= ការងារកសិកម្មក្នុងភូមិ ៣= ការងារផ្សេងៗក្រៅភូមិ (ក្នុងកម្ពុជា) ៤= ចំណាកស្រុកទៅថៃ ៥= ចំណាកស្រុកទៅព្រំដែនថៃ ៦= លក់ដូរតូចតាច ៧= ឡើងត្នោត ៨= នេសាទ ៩= ប្រមូលធនធានផ្សេងៗពីទឹក ឬទីវាល ១០=ប្រមូលធនធានផ្សេងៗពី ព្រៃឈើ ១១= មន្ត្រីរាជការ ១២= ផ្សេងៗទៀត............

| ប្រភពចំណូល | លេខលំដាប់ |
|---|---|
| | ប្រភពចំណូលសំខាន់ជាងគេ |
| | ប្រភពចំណូលទីពីរ |
| | ប្រភពចំណូលទីបី |

## II ធនធានដែលផ្តល់ដោយប្រព័ន្ធអេកូឡូស៊ី និងមុខនាទីទាក់ទងទៅនឹងវប្បធម៌

2.1. តើមានប្រភេទធនធានអ្វីខ្លះដែលអ្នកបានប្រមូល និង ប្រើប្រាស់?

| ១. ប្រភេទធនធាន | ២. ម្ចាស់កម្មសិទ្ធិ (កូដម្ចាស់កម្មសិទ្ធិ) | ៣. ផ្ទៃដីប្រហាក់ប្រហែល (ហត) | អ្នកប្រើប្រាស់សំខាន់ៗ (អតិ. ៥) | | | | | ផលិតផលសំខាន់ៗ (អតិ. ៥) (កូដផលិតផល) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 4. 1st | 5. 2nd | 6. 3rd | 7. 4th | 8. 5th | 9. 1st | 10. 2nd | 11. 3rd | 12. 4th | 13. 5th |
| ***១. អាហារដែលបានមកពីដីព្រៃ (ផលិតផលព្រៃឈើ)***<br>១. រុក្ខជាតិតូចៗ និងស្លឹក ២. ប្រភេទមើម ឬដើម ៣. ផ្លែឈើព្រៃ ៤. ថនិកសត្វ ៥. សត្វល្មិត ៦. សត្វស្លាប ៧. កង្កែប គីង្គក់ ៨. ក្តាម គ្រុំ ងាវ ខ្យង ៩. ល្អូន(ពស់ អណ្តើក) ១០. អាហារកែច្នៃ ១១. ផ្សេងៗទៀត:………… | | | | | | | | | | | | |
| ***២. ផលិតផលឈើ និងប្រភេទរុក្ខជាតិសរសៃផ្សេងទៀត***<br>១. ឈើហ៊ុប ២. ឈើបង្គោល ៣. ឈើកែច្នៃ (បន្ទះក្តារ ឧបករណ៍ផ្សេងៗ) ៤. ឈើសំភារៈសំណង់ ៥. ជ័រឈើ ៦. ឫស្សី ៧. ផ្តៅ ៨. កប្បាស ៩. ក្រចៅ ១០. សូត្រ ១១. ដទៃទៀត បញ្ជាក់:……… | | | | | | | | | | | | |
| ***៣. ឱសថបូរាណធម្មជាតិ***<br>១. ផ្សំពីរុក្ខជាតិ (ដើម សំបក ស្លឹក មើម ឫស) ២. ផ្សំពីសត្វព្រៃ ៣. ផ្សំពីរុក្ខជាតិតូចៗ (ប្រភេទស្មៅ) ៤. ទឹកឃ្មុំ ៥. ផ្សេងទៀត បញ្ជាក់:…… | | | | | | | | | | | | |
| ***៤. ថាមពលជីវម៉ាស***<br>១. ឧសធំៗ ២. ឧសធ្វើធ្យូង ៣. ឧសមែកឈើ ៤. លាមកសត្វ ៥. ផ្សេងទៀត បញ្ជាក់:………….. | | | | | | | | | | | | |
| ***៥. ដំណាំ***<br>១. ផ្លែឈើ ២. ស្រូវ ៣. បន្លែ ៤. ពោត ៥. ដំឡូងជ្វា ៦. សណ្តែកសៀង ៧. សណ្តែកបាយ ៨. ល្ង ៩. សណ្តែកដី ១០. ឪឡឹក ១១.ដំឡូងឈើ ១២= ផ្សេងទៀត (សូមបញ្ជាក់)………………. | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ***៦. ជីសម្រាប់ដាក់ក្នុងវាលស្រែ ចំការ***<br>១. ជីលាមកសត្វ ២. ជីកំប៉ុស្ត ៣. ជី អ៊ីអែម ៤. ជីគីមី<br>៥. ផ្សេងទៀត បញ្ជាក់:............. | | | | | | | | | | | | |
| ***៧. ប្រភេទអាហារផ្សេងទៀត ( មិនដាំ និង មិនចិញ្ចឹម ) ប្រមូលពីវាលស្រែ ចំការ និង តំបន់ផ្សេងទៀត ( មិនមែន ប្រមូលមកពីព្រៃ )***<br>១. រុក្ខជាតិតូចៗ និងស្លឹក ២. ប្រភេទមើម ឬដើម ៣. ផ្លែឈើ<br>៤. ថនិកសត្វ ៥. សត្វល្មិត ៦. សត្វស្លាប ៧. កង្កែប គីង្គក់ ៨. ក្តាម គ្រុំ ងាវ ខ្យង ៩. ល្អូន( ពស់ អណ្តើក ) ១០. អាហារកែច្នៃ ១១. ផ្សេងៗទៀត:......... | | | | | | | | | | | | |
| ***៨. ការនេសាទត្រី ( ពីទន្លេ ស្ទឹង បឹង ត្រពាំងធម្មជាតិ សមុទ្រ... )***<br>១. ត្រីទឹកសាប ២. កំពឹស ៣.បង្កងទន្លេ ៤. កង្កែប គីង្គក់ ៥. ក្តាម ៦. គ្រុំ ងាវ ខ្យង ៧. ត្រីសមុទ្រ ៨. បង្គារ ៩. បង្កងសមុទ្រ ១០. ក្តាមសមុទ្រ<br>១១. គ្រុំ ងាវសមុទ្រ ១២. ស្មៅសមុទ្រ ១៣. ផ្កាសមុទ្រ ១៤. សារ៉ាយ<br>១៥. ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | |
| ***៩. វារីវប្បកម្ម ( ការចិញ្ចឹមត្រី )***<br>១. ត្រីទឹកសាប ២. កំពឹស ៣.បង្កងទន្លេ ៤. កង្កែប គីង្គក់ ៥. ក្តាម ៦. គ្រុំ ងាវ ខ្យង ៧. ត្រីសមុទ្រ ៨. បង្គារ ៩. បង្កងសមុទ្រ ១០. ក្តាមសមុទ្រ<br>១១. គ្រុំ ងាវសមុទ្រ ១២. ស្មៅសមុទ្រ ១៣. ផ្កាសមុទ្រ ១៤. សារ៉ាយ<br>១៥. ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | |
| ***១០. ការចិញ្ចឹមសត្វ***<br>១. គោ ២. ក្របី ៣. ជ្រូក ៤. មាន់ ៥. ទា ៦.ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | |
| ***១១. ទឹកលើដី ( ទឹកទន្លេ បឹង ស្ទឹង អូរ សមុទ្រ... )***<br>១. ទឹកសម្រាប់បរិភោគ និងចំអិនអាហារ ២. ទឹកសម្រាប់លាងសំអាត<br>៣. ទឹកសម្រាប់ងូត ៤.ផ្លូវទឹកសម្រាប់ធ្វើដំណើរ ៥. ទឹកសម្រាប់ ស្រោចដំណាំ ៦. ទឹកសម្រាប់ប្រើក្នុងឧស្សាហកម្មធនតូច ៧. ផលិតអំបិល<br>៨. ផ្សេងទៀត បញ្ជាក់:............... | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ***១២. ទឹកក្រោមដី*** *(ទឹកអណ្តូង...)*<br>១. ទឹកសម្រាប់បរិភោគ និងចំអិនអាហារ ២. ទឹកសម្រាប់លាងសំអាត<br>៣. ទឹកសម្រាប់ងូត ៤. ទឹកសម្រាប់ស្រោចដំណាំ ៥. ទឹកសម្រាប់ប្រើ ក្នុងឧស្សាហកម្មធនតូច ៦. ផ្សេងទៀត បញ្ជាក់:............... | | | | | | | | | | | | |
| ***១៣. ទឹកភ្លៀង***<br>១. ទឹកសម្រាប់បរិភោគ និងចំអិនអាហារ ២. ទឹកសម្រាប់លាងសំអាត<br>៣. ទឹកសម្រាប់ងូត ៤. ទឹកសម្រាប់ស្រោចដំណាំ ៥. ទឹកសម្រាប់ប្រើក្នុងឧស្សាហកម្មធនតូច ៦. ផ្សេងទៀត បញ្ជាក់:............... | | | | | | | | | | | | |
| ***១៤. ទេសចរណ៍*** *(ប្រាក់ចំណូលដែលបានមកពីភ្ញៀវទេសចរ ការដើរកំសាន្តនៅជុំវិញតំបន់)*<br>១. ការស្នាក់នៅ ២. ការណែនាំផ្លូវ ៣. ការបម្រើអាហារ<br>៤. ផ្សេងទៀត បញ្ជាក់:............. | | | | | | | | ***តើអ្នកទទួលបានប្រាក់ចំណូលតាមរយៈសេវាកម្មអ្វីខ្លះ?*** | | | | |

*១) "អ្នកប្រើប្រាស់សំខាន់ៗ" គឺផ្តោតទៅលើអ្នកណាដែលទទួលបានផលិតផលដែលមានតម្លៃខ្ពស់ជាងគេ (សម្រាប់ផ្គត់ផ្គង់គ្រួសារ និងលក់) ពីប្រភេទប្រព័ន្ធអេកូឡូស៊ីណាមួយក្នុងរយៈពេល ១២ខែកន្លងមក ។*

**កូដ: សូមជ្រើសរើសកូដដែលសមស្របបំផុតពី បណ្តាចំណុចខាងក្រោម** (**មួយចំនួនដូចគ្នា**)

១= អ្នកភូមិដែលជាសមាជិករបស់ "សហគមន៍"
២= អ្នកភូមិដែលមិនមែនជាសមាជិករបស់ "សហគមន៍"
៣= សម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារនៅក្នុងភូមិ
៤=ប្រើប្រាស់សម្រាប់ពាណិជ្ជកម្មខ្នាតតូចនៅក្នុងភូមិ
៥= ប្រើប្រាស់សម្រាប់ពាណិជ្ជកម្មខ្នាតធំនៅក្នុងភូមិ
៦= សម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសាររបស់អ្នកមកពីក្រៅភូមិ
៧=ប្រើប្រាស់សម្រាប់ពាណិជ្ជកម្មខ្នាតតូចរបស់អ្នកមកពីក្រៅភូមិ
៨=ប្រើប្រាស់សម្រាប់ពាណិជ្ជកម្មខ្នាតធំរបស់អ្នកមកពីក្រៅភូមិ
៩=ផ្សេងទៀត បញ្ជាក់:.............

2.2. តើមានបរិមាណ និងតម្លៃប៉ុន្មានដែលសមាជិកគ្រួសារបានប្រមូលសម្រាប់ប្រើប្រាស់ និងសម្រាប់លក់ក្នុងឆ្នាំមុនពីប្រព័ន្ធអេកូឡូស៊ីនីមួយៗ?

| **រដូវកាល** | **រដូវប្រាំង** | | | | | | | | | **រដូវវស្សា** | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1. **សេវាកម្មផ្គត់ផ្គង់ និងរបបធម៌** | 2. **ប្រមូលផលដោយនរណា?** | 3. **ប្រមូលផលនៅទីណា?** | | 4. **ឯកតា** | 5. **ប្រើផ្ទាល់ខ្លួន** (**រួមទាំងអំណោយ**) | 6. **លក់** (**រួមទាំងដោះដូរ**) | 7. **តម្លៃ១ឯកតា** | 8. **ប្រភេទទីផ្សារ** (**កូដទីផ្សារ**) | 9. **ថ្លៃដើមនិងផ្តួលពលកម្ម** | 2. **ប្រមូលផលដោយនរណា?** | 3. **ប្រមូលផលនៅទីណា?** | | 4. **ឯកតា** | 5. **ប្រើផ្ទាល់ខ្លួន** (**រួមទាំងអំណោយ**) | 6. **លក់** (**រួមទាំងដោះដូរ**) | 7. **តម្លៃ១ឯកតា** | 8. **ប្រភេទទីផ្សារ** (**កូដទីផ្សារ**) | 9. **ថ្លៃដើមនិងផ្តួលពលកម្ម** |
| | | **ប្រភេទដី** (***កូដដី***) | **កម្មសិទ្ធិ** (***កូដកម្មសិទ្ធិ***) | | | | | | | | **ប្រភេទដី** (***កូដដី***) | **កម្មសិទ្ធិ** (***កូដកម្មសិទ្ធិ***) | | | | | | |
| ***១. អាហារដែលបានមកពីដីព្រៃ*** *(ផលិតផលព្រៃឈើ)* ១. រុក្ខជាតិ&ស្លឹកឈើហូបបាន ២. មើម & ឫសហូបបាន ៣. ផ្លែឈើព្រៃ ៤. សត្វព្រៃ (ថនិកសត្វ) ៥. សត្វល្អិត ៦. បក្សីព្រៃ ៧. មណ្ឌកសត្វ ៨. សត្វសំបករឹង (ក្តាម ខ្យង បង្កង) ៩. ពពួកល្ហុន ១០. ផលិតផលអាហារព្រៃកែច្នៃ ១១. ផ្សេងទៀត បញ្ជាក់.......... | | | | | | | | | | | | | | | | | | |
| ***២. ផលិតផលឈើ និង ប្រភេទរុក្ខជាតិសរសៃផ្សេងទៀត*** ១. ឈើ ២. សរសរ ៣. ឈើកែច្នៃរួច (ឈើអារ ឧបករណ៍) ៤. សម្ភារៈសំណង់ ៥. ជ័រឈើ ៦. ឫស្សី ៧. ផ្តៅ ៨. កប្បាស ៩. ដើមក្រចៅ ១០. សរសៃសូត្រ ១១. ផ្សេងទៀត បញ្ជាក់............. | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ***៣. ឱសថបុរាណធម្មជាតិ***<br>១. ផ្នែកផ្សេងៗពីដើមឈើ (ដើមឈើ សំបក ស្លឹក ឫសឈើ...) ២. ស្លឹកឈើព្រៃ ៣. ដើមរុក្ខជាតិ (ដូចជា ពពួកមើម) ៤. ទឹកឃ្មុំ<br>៥. ផ្សេងទៀត បញ្ជាក់............. | | | | | | | | | | | | | | | | | | |
| ***៤. ថាមពលជីវៈ***<br>***ម៉ាស***<br>១. ឧស ២. ឈើឧសសម្រាប់ផលិតធ្យូង ៣. មែកឈើតូចៗ ៤. អាចម៍សត្វ<br>៥. ផ្សេងទៀតបញ្ជាក់......... | | | | | | | | | | | | | | | | | | |
| ***៥. ដំណាំ*** | | | | | | | | | | | | | | | | | | |
| ***៦. បន្លែ*** | | | | | | | | | | | | | | | | | | |
| ***៧. ផ្លែឈើ*** | | | | | | | | | | | | | | | | | | |
| ***៨. ជីសម្រាប់ដាក់ក្នុងវាលស្រែ ចំការ***<br>១. ជីលាមកសត្វ ២. ជីកំប៉ុស្ត ៣. ជី អ៊ីអែម ៤. ជីគីមី ៥. ផ្សេងទៀត បញ្ជាក់:............. | | | | | | | | | | | | | | | | | | |
| ***៩. ប្រភេទអាហារ ផ្សេងទៀត*** *(មិនដាំ និង មិនចិញ្ចឹម) ប្រមូលពីវាលស្រែ ចំការ និង តំបន់ផ្សេងទៀត (មិនមែនប្រមូលមកពីព្រៃ)*<br>១. រុក្ខជាតិ&ស្លឹកឈើហូបបាន ២. មើម & ឫសហូបបាន ៣. ផ្លែឈើព្រៃ ៤. សត្វព្រៃ (ថនិកសត្វ) ៥. សត្វល្អិត ៦. បក្សីព្រៃ ៧. មណ្ឌកសត្វព្រៃ ៨. សត្វសំបករឹង (ក្តាម ខ្យង បង្កង) ៩. សត្វល្មូន ១០. ផលិតផលអាហារព្រៃកែច្នៃរួច<br>១១. ផ្សេងទៀតបញ្ជាក់.................. | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ***១០. ការនេសាទត្រី*** *(ពីទន្លេ ស្ទឹង បឹង ត្រពាំងធម្មជាតិ)*<br>១. ត្រីទឹកសាប ២. កំពឹស ៣. បង្កងទន្លេ<br>៤. កង្កែប គីង្គក់ ៥. ក្តាម ៦.គ្រុំ ងាវ ខ្យង<br>៧. ត្រីសមុទ្រ ៨. បង្គារ ៩. បង្កងសមុទ្រ<br>១០. ក្តាមសមុទ្រ ១១. គ្រុំ ងាវសមុទ្រ ១២. ស្មៅសមុទ្រ ១៣. ផ្កាសមុទ្រ ១៤. សារ៉ាយ<br>១៥. ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | | | | | | | |
| ***១១. វារីវប្បកម្ម*** *(ការចិញ្ចឹមត្រី)*<br>១. ត្រីទឹកសាប ២. កំពឹស ៣. បង្កងទន្លេ ៤. កង្កែប គីង្គក់ ៥. ក្តាម ៦. គ្រុំ ងាវ ខ្យង ៧. ត្រីសមុទ្រ ៨. បង្គារ ៩. បង្កងសមុទ្រ<br>១០. ក្តាមសមុទ្រ ១១. គ្រុំ ងាវសមុទ្រ ១២. ស្មៅសមុទ្រ ១៣. ផ្កាសមុទ្រ ១៤. សារ៉ាយ<br>១៥. ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | | | | | | | |
| ***១២. ការចិញ្ចឹមសត្វ***<br>១. គោ ២. ក្របី ៣. ជ្រូក ៤. មាន់ ៥. ទា<br>៦. ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | | | | | | | |
| ***១៣. ទឹកលើដី*** *(ទឹកទន្លេ បឹង ស្ទឹង អូរ...)*<br>១. ទឹកសម្រាប់បរិភោគ និងចំអិនអាហារ ២. ទឹកសម្រាប់លាងសំអាត ៣.ទឹកសម្រាប់ងូត<br>៤. ផ្លូវទឹកសម្រាប់ធ្វើដំណើរ ៥. ទឹកសម្រាប់ស្រោចដំណាំ ៦. ទឹកសម្រាប់ប្រើក្នុងឧស្សាហកម្មធនតូច ៧. ផលិតអំបិល<br>៨. ផ្សេងទៀត បញ្ជាក់:............ | | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ***១៤. ទឹកក្រោមដី***<br>១.ទឹកសម្រាប់បរិភោគ និងចំអិនអាហារ<br>២.ទឹកសម្រាប់លាងសំអាត ៣.ទឹកសម្រាប់ងូត<br>៤.ទឹកសម្រាប់ស្រោចដំណាំ<br>៥.ទឹកសម្រាប់ប្រើក្នុងឧស្សាហកម្មធនតូច<br>៦.ផ្សេងទៀត បញ្ជាក់:......... | | | | | | | | | | | | | | | | | | |
| ***១៥. ទឹកភ្លៀង***<br>១.ទឹកសម្រាប់បរិភោគ និងចំអិនអាហារ<br>២.ទឹកសម្រាប់លាងសំអាត ៣.ទឹកសម្រាប់ងូត<br>៤.ទឹកសម្រាប់ស្រោចដំណាំ<br>៥.ទឹកសម្រាប់ប្រើក្នុងឧស្សាហកម្មធនតូច<br>៦.ផ្សេងទៀត បញ្ជាក់:......... | | | | | | | | | | | | | | | | | | |
| ***១៦. ទេសចរណ៍***<br>១.ការស្នាក់នៅ ២.ការណែនាំផ្លូវ<br>៣.ការបម្រើអាហារ<br>៤.ផ្សេងទៀត បញ្ជាក់:............. | (រៀល) | | | | | | | | | (រៀល) | | | | | | | | |

## 2.3. ទំនោរ និងស្ថានភាពនៃធនធាន

| **១. អាហារដែលបានមកពីដីព្រៃ (ផលិតផលព្រៃឈើ)**<br>១. រុក្ខជាតិតូចៗ និងស្លឹក ២. ប្រភេទមើម ឬ ដើម ៣. ផ្លែឈើព្រៃ ៤. ថនិកសត្វ ៥. សត្វល្អិត ៦. សត្វស្លាប ៧. កង្កែប គីង្គក់ ៨. ក្តាម គ្រំ ងាវ ខ្យង ៩. ល្មូន(ពស់ អណ្តើក) ១០. អាហារកែច្នៃ<br>១១. ផ្សេងៗទៀតៈ........................ | ប្រសិននៅឆ្នាំ ១៩៩៩ អ្នកអាចប្រមូលបាន ១០០% | តើនៅឆ្នាំ២០០០ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០១ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០២ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០៣ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០៤ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០៥ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០៦ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០៧ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? | តើនៅឆ្នាំ២០០៨ អ្នកអាចប្រមូលបានប៉ុន្មានភាគរយ? |
|---|---|---|---|---|---|---|---|---|---|---|
| ទីមួយៈ......................................... | | | | | | | | | | |
| ហេតុអ្វី? .......................................... | | | | | | | | | | |
| វិធានការដោះស្រាយ......................................... | | | | | | | | | | |
| ទីពីរ.......................................... | | | | | | | | | | |
| ហេតុអ្វី?............................................................. ................... | | | | | | | | | | |
| វិធានការដោះស្រាយ......................................... | | | | | | | | | | |
| ទីបី.......................................... | | | | | | | | | | |
